គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge



# ការចូលរួមពីមូលដ្ឋានដើម្បី ធ្វើសកម្មភាព ដោះស្រាយបញ្ហាសហគមន៍

ខែវិច្ឆិកា ឆ្នាំ២០១៣

## ករណីសិក្សាសង្ខេប
## វគ្គសហគមន៍សម្រាប់ការសិក្សាស្រាវជ្រាវ
## ដោយមានការចូលរួមដើម្បីធ្វើសកម្មភាព

Promoting NGO Solidarity and Cooperation Since 1990

# ការចូលរួមពីមូលដ្ឋានដើម្បី

# ធ្វើសកម្មភាព

# ដោះស្រាយបញ្ហាសហគមន៍

ករណីសិក្សាសង្ខេប

វគ្គសហគមន៍សម្រាប់ការសិក្សាស្រាវជ្រាវ

ដោយមានការចូលរួមដើម្បីធ្វើសកម្មភាព

ខែវិច្ឆិកា ឆ្នាំ២០១៣

# មាតិកា


មាតិកា ..... 2

បុព្វកថា ..... 3

សេចក្តីផ្តើម ..... 4

- ចលនាសហគមន៍ដើម្បីការធ្វើចំណាកស្រុក ប្រកបដោយសុវត្ថិភាព ..... 6
- លើកកម្ពស់ការថែទាំសុខភាពបឋម និងអនាម័យ នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ..... 9
- ប្រព័ន្ធធ្វើស្រែសម្រាប់កសិករនៅ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ..... 13
- ចលនាការចូលរួមលើកកម្ពស់ការថែទាំសុខុមាលភាពសហគមន៍ នៅស្រុកអូររាំងឪ ខេត្តកំពង់ចាម ..... 17
- ប្រជាសហគមន៍ចូលរួមលើកកម្ពស់អនាម័យ និងសុខភាពបឋម នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ..... 20
- ការចូលរួមលើកកម្ពស់វិស័យអប់រំនៅសាលាបឋមសិក្សាជនបទ ..... 23
- ការពង្រឹងកិច្ចគាំពារព្រៃឈើ និង សហគមន៍ ..... 26

ឧបសម្ព័ន្ធ ១: អង្គការជាសិក្ខាកាម ..... 31

ឧបសម្ព័ន្ធ ២: ក្រុមការងាររបស់អង្គការ CCC ..... 31

# បុព្វកថា

កម្ពុជាមានដំណើរការរីកចំរើនគួរអោយកត់សំគាល់ក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ។ អង្គការសង្គមស៊ីវិលត្រូវបានគេទទួលស្គាល់យ៉ាងសំខាន់ក្នុងដំណើររួមចំណែក និងចូលរួមយ៉ាងសកម្មក្នុងកិច្ចអភិវឌ្ឍនេះ។ ទន្ទឹមនឹងនេះ អង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) បានដើរតួនាទី ជាពិសេសតាំងពីឆ្នាំ១៩៩០ ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការងារបណ្តាញ តាមរយៈធ្វើការងាររួមគ្នាជាមួយអង្គការសមាជិក និងតួអង្គអភិវឌ្ឍផ្សេងៗ ក្នុងការដោះស្រាយបញ្ហាប្រឈម នៅកម្ពុជា។ ក្រៅពីសកម្មភាពទាំងនេះ ការអភិវឌ្ឍសមត្ថភាព គឺជារបៀបវារៈមួយយ៉ាងសំខាន់ ក្នុងការជម្រុញប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងដំណើរការសកម្មភាព ក៏ដូចជាឆ្លើយតបកាន់តែប្រសើរ ស្របតាមការវិវត្តនិន្នាការ និងបញ្ហាប្រឈម។ អង្គការ CCC បានផ្តល់ការសិក្សារៀនសូត្រទាំងការងារ គ្រប់គ្រង ការប្រតិបត្តិ ព្រមទាំងសកម្មភាពស្រាវជ្រាវសម្រាប់គោលនយោបាយ និងស្រាវជ្រាវដើម្បីធ្វើ សកម្មភាពសម្រាប់ការបំពេញគ្នា ទៅវិញទៅមកក្នុងយន្តការអភិវឌ្ឍទាំងថ្នាក់ជាតិ និងមូលដ្ឋាន។

ដូចនេះអង្គការ CCC បានរៀបចំការកសាងសមត្ថភាពជាពិសេស តាំងពីឆ្នាំ២០០៤ សម្រាប់អ្នកធ្វើការសហគមន៍ ដែលធ្លាប់ស្គាល់ថា វគ្គសហគមន៍ និងបន្តកែសម្រួលអោយស្របតាមតម្រូវការរបស់ អង្គការមិនមែនរដ្ឋាភិបាល ដែលជាលទ្ធផល សិក្ខាកាមបានសិក្សារៀនសូត្រ ចែករំលែកទ្រឹស្តី ការអនុវត្ត និងវិធីសាស្ត្រលើការងារអភិវឌ្ឍ ព្រមទាំងរុករក និងធ្វើការដោះស្រាយបញ្ហានៃការសិក្សាស្រាវជ្រាវ នៅតាមសហគមន៍ ដើម្បីដោះស្រាយបញ្ហាដោយមានការចូលរួម។ ជាងនេះទៅទៀតលទ្ធផលទាំងនោះ អាចជួយបន្ថែម សម្រាប់ការរៀបចំផែនការកម្មវិធី និងអនុវត្តក្នុងអង្គការនិងសហគមន៍កាន់តែប្រសើរឡើង។

របាយការណ៍សង្ខេបនេះ មានចំណងជើង "ការចូលរួមពីមូលដ្ឋានដើម្បីធ្វើសកម្មភាពដោះស្រាយបញ្ហាសហគមន៍"ដែលបានទាញនូវព័ត៌មានសំខាន់ៗចេញពីរបាយការណ៍សិក្សាលំអិតធ្វើឡើងដោយអង្គការចំនួន១៥ ដែលបានចូលរួមវគ្គសហគមន៍សម្រាប់ការសិក្សាស្រាវជ្រាវ ដោយមានការចូលរួមដើម្បីធ្វើសកម្មភាព (CPAR) ក្នុងឆ្នាំ២០១៣។ បញ្ហាការស្រាវជ្រាវនេះ បានលេចឡើងផ្សេងៗទាក់ទងនឹងសង្គមសេដ្ឋកិច្ច និងបញ្ហាបរិស្ថាន ឆ្លងតាមការឆ្លុះបញ្ចាំង ក្នុងតំបន់ការងាររបស់អង្គការហើយអនុវត្តការស្រាវជ្រាវតាមបែបចូលរួមដើម្បីធ្វើសកម្មភាព ក្នុងឃុំចំនួនប្រាំពី នៃខេត្តចំនួនបួន។

សូមអរគុណដល់អ្នកចូលរួមសកម្មភាពស្រាវជ្រាវនេះ ដែលបានខិតខំ ដើម្បីទទួលបាន ផលយ៉ាងច្រើន និងទទួលបានមេរៀនជាបទពិសោធន៍ពីការធ្វើសកម្មភាពទាំងនេះ សម្រាប់រួមចំណែកក្នុងដំណើរវិវត្តន៍ក្នុងសហគមន៍។ យើងខ្ញុំ ក្នុងនាមអង្គការ CCC សង្ឃឹមថា របាយការសង្ខេបនេះនឹងជួយលើកកម្ពស់ពីភាពចាំបាច់ និងជោគជ័យចេញពីការសិក្សាស្រាវជ្រាវតាមបែបចូលរួម ដើម្បីធ្វើសកម្មភាពក្នុងការដោះស្រាយបញ្ហាសហគមន៍ និងការចូលរួមពង្រឹងសិទ្ធអំណាចសហគមន៍មូលដ្ឋាន។

**សឿង សារឿន**

នាយកប្រតិបត្តិ

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)

# សេចក្តីផ្តើម

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) គឺជាអង្គការសមាជិកភាពឈានមុខគេដែលបានបង្កើតឡើងតាំងពីឆ្នាំ១៩៩០ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ អភិបាលកិច្ច ភាពវិជ្ជាជីវៈ គណនេយ្យភាព បរិយាកាសអំណោយផល និងប្រសិទ្ធភាពនៃការអភិវឌ្ឍ របស់អង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការអភិវឌ្ឍលើផ្នែកផ្សេងៗ នៅក្នុងប្រទេសកម្ពុជា។ ប្រវត្តិយូរអង្វែង និងសកម្មភាពការងារលើវិស័យទាំងនេះ បានសម្របសម្រួល និងកសាងសមត្ថភាពគួរជាទីពេញចិត្ត សម្រាប់អង្គការសមាជិក និងអង្គការសង្គមស៊ីវិលជាដៃគូដទៃទៀត តាមរយៈការជួយគាំទ្រសកម្មភាព ដែលបានផ្តល់ជូនទាំងលើផ្នែកកម្មវិធី ស្ថាប័ន និង របៀបនៃការអនុវត្តការងារជាមួយប្រជាសហគមន៍ ក្នុងការផ្តល់ផលជាវិជ្ជមាន និង ចូលរួមចំណែកយ៉ាងសំខាន់ ដល់ការអភិវឌ្ឍប្រទេសកម្ពុជា ដ៏គួរឲ្យកត់សម្គាល់។

ក្រោមគម្រោងមជ្ឈមណ្ឌលអភិបាលកិច្ច ការកសាងសមត្ថភាព និងការសិក្សារៀនសូត្រ ដែលស្ថិតក្នុងសមាសភាពទី២ បានបន្តអនុវត្ត វគ្គបណ្តុះបណ្តាលស្តីពី **សហគមន៍សម្រាប់ការសិក្សាស្រាវជ្រាវដោយមានការចូលរួមដើម្បីធ្វើសកម្មភាព** (CPAR) ដែលបានបានស្គាល់ថា វគ្គសហគមន៍ បានផ្តល់ជូនដោយអង្គការ CCC តាំងពីឆ្នាំ ២០០៤។ វគ្គនេះត្រូវបានកែសំរួលជាថ្មី ដើម្បីឆ្លើយតបអោយកាន់តែល្អប្រសើរសម្រាប់អ្នកបម្រើការងារផ្ទាល់នៅមូលដ្ឋាន សម្រាប់ការរៀនសូត្រនិងដោះស្រាយបញ្ហា។ វគ្គសិក្សានេះ មានបំណងពង្រឹងសមត្ថភាពស្រាវជ្រាវ និងជំនាញវិភាគលើបញ្ហាដែលលេចឡើងថ្មីៗ និងជះឥទ្ធិពលលើការគិត និងការអនុវត្តជាក់ស្តែងរបស់សិក្ខាកាម ដើម្បីពង្រឹងអំណាចដល់សហគមន៍មូលដ្ឋាន និងជាការឆ្លើយតបទៅនឹង ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សក្នុងសង្គមកម្ពុជា។

ក្នុងឆ្នាំ ២០១៣ នេះ កំឡុងពេលនៃវគ្គចាប់ផ្តើមពីចុងខែមីនា និងបញ្ចប់ក្នុងខែសីហា ដែលបែងចែកជាបីជំហាន: ១)សិក្សាពីបញ្ញាត្តិ និងទ្រឹស្តីសំខាន់ៗទាក់ទងនឹងការសិក្សាស្រាវជ្រាវ ការងារអភិវឌ្ឍ និងការផ្លាស់ប្តូរសង្គម ការអភិវឌ្ឍផ្តោតលើសិទ្ធិជាមូលដ្ឋាន ជាដើម ព្រមទាំងមានការដឹកនាំសម្រាប់ចូលរួមអនុវត្តជាក់ស្តែង ២) រៀបចំដំណើរការអនុវត្តការសិក្សាស្រាវជ្រាវ តាមតំបន់គោលដៅរបស់សិក្ខាកាម ដោយផ្តោតជាសំខាន់លើការប្រើប្រាស់ ការសិក្សាស្រាវជ្រាវតាមបែបចូលរួម ដើម្បីធ្វើសកម្មភាព (PAR) ក្នុងគោលបំណងរួមចំណែកដោះស្រាយបញ្ហា សហគមន៍។ ការគាំទ្រផ្នែកបច្ចេកទេស ត្រូវបានផ្តល់ តាមរយៈ ការណែនាំ និងហ្វឹកហាត់ពីក្រុមអ្នកបណ្តុះបណ្តាលរបស់អង្គការ CCC ក្នុងដំណើរការនេះ និង ៣) ការសរសេររបាយការណ៍បញ្ចប់ ការធ្វើបទបង្ហាញ និង ឆ្លុះបញ្ចាំងការសិក្សារៀនសូត្រក្នុងវគ្គ។




ប្រភព : Yoland Wadsworth អ្វីជាសកម្មភាពស្រាវជ្រាវដោយមានការចូលរួម? សកម្មភាពស្រាវជ្រាវអន្តរជាតិ ខែវិច្ឆិកា ឆ្នាំ១៩៩៨

ខ្លឹមសារវគ្គបានប្រើប្រាស់ យ៉ាងសំខាន់លើវិធីសាស្ត្រស្រាវជ្រាវដោយមានការចូលរួម ដើម្បីធ្វើសកម្មភាព (PAR) ដែលសម្រួលយកពីលំនាំគំរូរបស់ Wadsworth ឆ្នាំ១៩៩៨[1]។ វាមានដំណើរការជាវដ្ត ដែលចាប់ផ្តើមជាមួយៈ i) ការឆ្លុះបញ្ចាំងលើស្ថានភាពបច្ចុប្បន្ន តាមរយៈកិច្ចពិភាក្សានិងការសង្កេតជាមួយអ្នកពាក់ព័ន្ធ ក្នុងសហគមន៍ និង បុគ្គលសំខាន់ៗ ii) ស្វែងរកបញ្ហា ឬជាសំណួរជាក់លាក់ iii) ការចុះប្រមូលព័ត៌មាន និង iv)ការវិភាគ ដើម្បីឈានទៅ ការរៀបចំជាផែនការសកម្មភាព នឹងនាំមកនូវការសិក្សារៀនសូត្រ ដើម្បីការផ្លាស់ប្តូរស្ថានភាព។

អ្នកចូលរួមក្នុងវគ្គនេះបានសម្របសម្រួលដំណើរការ និងនាំមកនូវការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក និងការផ្លាស់ប្តូរ ព្រមទាំងធ្វើអោយមានការចូលរួមពីអ្នកពាក់ព័ន្ធ ជាពិសេសអ្នកភូមិក្នុងដំណើរការទាំងនេះ។ អង្គការដែលចូលរួមទាំងឡាយ ធ្វើការលើបញ្ហាមួយដែលទាក់ទិន នឹងការងារកម្មវិធីរបស់ពួកគេ និងមិនប៉ះពាល់ជាសំខាន់ដល់ការងារស្នូលផ្សេងទៀតក្នុងគម្រោងការងាររបស់ខ្លួន ដើម្បីចូលរួមអនុវត្តការងារនេះអោយកាន់តែមានប្រសិទ្ធភាព នៅតែបន្ត ទោះបីជារយៈពេលវគ្គត្រូវបានបញ្ចប់។ អ្នកសម្របសម្រួលបានស្នាក់នៅក្នុងភូមិគោលដៅ ដើម្បីប្រមូលព័ត៌មាន ដោយមានការចូលរួមពីអ្នកភូមិមូលដ្ឋាន។ រាល់ព័ត៌មានទាំងអស់ដែលបានប្រមូល ត្រូវបានឆ្លុះបញ្ចាំង និងពិភាក្សា ដើម្បីវិភាគស៊ីជម្រៅ និងឈានដល់ឫសគល់ និងផលប៉ះពាល់ ដើម្បីរិះរកវិធីប្រសើរ ក្នុងការដោះស្រាយបញ្ហាតាមការរៀបចំចេញជាផែនការជាក់លាក់។ វាគឺជាវដ្តនៃដំណើរការ សិក្ខាកាម បានឆ្លុះបញ្ចាំងជាមួយភាគីពាក់ព័ន្ធក្នុងសហគមន៍ ដើម្បីពិនិត្យមើលពីលទ្ធផល និងសន្និដ្ឋានលើដំណើរការកន្លងមក ព្រមទាំងទាញយក នូវចំនុចសិក្សារៀនសូត្រ ថាតើគួររៀបចំផែនការសកម្មភាពអ្វីបន្តទៀត សម្រាប់ការប្រែប្រួលស្ថានភាពនៃបញ្ហា។

នេះគឺជាសេចក្តីសង្ខេបនៃលទ្ធផលស្រាវជ្រាវពីសិក្ខាកាមអង្គការមិនមែនរដ្ឋាភិបាលចំនួន ១៥ នាក់ (សូមមើលឧបសម្ព័ន្ធ) ដែលបានអនុវត្តការស្រាវជ្រាវរបស់ខ្លួន ក្នុងឆ្នាំ ២០១៣។ ប្រធានបទភាគច្រើនត្រូវបានជ្រើសរើសតាមតំបន់ដែលមានកង្វល់ច្រើន ព្រមទាំងបានគិតពិចារណាផងដែរពីកំរិតដែលអាចចូលរួមដោះស្រាយបញ្ហា និងទាញយកការសិក្សារៀនសូត្រ ក្នុងរយៈពេលនៃវគ្គសិក្សា ៥ខែ។ ប្រធានបទដែលបានលើក ឡើងនេះមានបញ្ហាផ្សេងៗដែលលេចឡើង ក្នុងតំបន់ រួមមានបរិស្ថាន សុខភាព និងអនាម័យ (ដែលទំនងជាមានការលេចឡើងច្រើនក្នុងតំបន់ជនបទ) ការអប់រំ និងបញ្ហាថ្មីៗផ្សេងទៀត នៅក្នុងសហគមន៍។ ប្រធានបទទាំងនេះ ត្រូវបានធ្វើការសិក្សាស្រាវជ្រាវ នៅក្នុងខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និង កំពង់ចាម។

[1] Yoland W. (1998), *What is Participatory Action Research?*, Action Research International.

# ចលនាសហគមន៍ដើម្បីការធ្វើចំណាកស្រុក ប្រកបដោយសុវត្ថិភាព

ការស្រាវជ្រាវសម្របសម្រួលដោយៈ ខ្លូត ផល្លី ម៉ែន សំភ័ណ និង មៅ គង្គា

ការធ្វើចំណាកស្រុក (ទាំងស្របច្បាប់ និងមិនស្របច្បាប់) បានក្លាយជាបញ្ហាមួយ និងកើតឡើងស្ទើរតែនៅគ្រប់ទីកន្លែងនៅកម្ពុជា។ ករណីនេះកើតឡើងច្រើនជាងគេនៅតាមខេត្តជាប់ព្រំដែននឹងប្រទេសថៃ និងវៀតណាម ដែលនៅទីនោះ ប្រជាជនវ័យលើស ១៥ ឆ្នាំ បានធ្វើចំណាកស្រុកដើម្បីស្វែងរកប្រភពប្រាក់ចំណូលបន្ថែម ក្រៅពីសកម្មភាពការងារស្នូលរបស់ពួកគេជាកសិកម្ម។ បទពិសោធន៍ និងករណីមិនល្អជាច្រើនត្រូវបានរាយការណ៍ និង ត្រូវបានគេឮយ៉ាងញឹកញាប់ ដែលនៅក្នុងនោះ ជនចំណាកស្រុកត្រូវបានរងការកេងប្រវ័ញ្ចពីសំណាក់មេខ្យល់ អ្នកមៅការ និង ចៅហ្វាយនាយ។

ជាលទ្ធផលនៃវគ្គបណ្តុះបណ្តាល ស្តីពីសហគមន៍សម្រាប់ការសិក្សាស្រាវជ្រាវដោយមានការចូលរួមដើម្បីធ្វើសកម្មភាព (CPAR) ដែលត្រូវបានរៀបចំធ្វើដោយអង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) នៅក្នុងខែមីនា ឆ្នាំ២០១៣ ការសិក្សាស្រាវជ្រាវជាក់ស្តែងត្រូវបានអនុវត្តដោយសិក្ខាកាមបីរូបពីអង្គការជួយជនចាស់ជរាអន្តរជាតិ-កម្ពុជា (Help Age International-Cambodia) ដែលបានធ្វើឡើងនៅភូមិទួលធ្នង់ និងភូមិស្វាយបីដើម ដើម្បីជំរុញឲ្យប្រជាជនក្នុងសហគមន៍ កំណត់បញ្ហាថ្មីៗដែលកើតឡើងក្នុងតំបន់របស់ពួកគេ យល់ពីមូលហេតុឫសគល់នៃបញ្ហា និង ធ្វើសកម្មភាពរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាទាំងនោះ។





ភូមិទួលធ្នង់ និង ភូមិស្វាយបីដើម គឺជាភូមិនៅជិតខាងគ្នា ស្ថិតក្នុងឃុំកន្ទឺ ១ ស្រុកបាណន់ ខេត្តបាត់ដំបង។ ភូមិទាំងនេះមានចម្ងាយ ៣០ គីឡូម៉ែត្រ ពីទីរួមខេត្តបាត់ដំបង។ ទោះបីជាប្រជាជនភាគច្រើនគឺជាកសិករធ្វើស្រែនិងធ្វើចំការក្តី ក៏ប្រភពប្រាក់ចំណូលចម្បងរបស់ពួកគេពីការងារកសិកម្មបានថយចុះពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារកង្វះប្រព័ន្ធស្រោចស្រព ថ្លៃចំណាយខ្ពស់សម្រាប់បំពេញ

សកម្មភាពកសិកម្ម ទីផ្សារមិនមានលក្ខណៈប្រកួតប្រជែង ។ល។ ជីវិតរស់នៅលែងមានលក្ខណៈងាយស្រួលទៀតហើយនៅក្នុងភូមិទាំងពីរ ហើយអ្នកភូមិខ្លះបានសម្រេចចិត្តធ្វើចំណាកស្រុក ដោយបន្សល់ទុកលំនៅឋាន ទ្រព្យសម្បត្តិ ឬ រហូតដល់ទៅកូនៗ របស់ពួកគេឲ្យនៅជាមួយជីដូនជីតា ឬសាច់ញាតិ។

តាមការសិក្សា មានកត្តានាំមុខចំនួនបីដែលជំរុញឲ្យប្រជាជនធ្វើចំណាកស្រុក ទាំងស្របច្បាប់ និងមិនស្របច្បាប់ ទៅកាន់ប្រទេសថៃ និង ប្រទេសជិតខាងផ្សេងទៀត ដើម្បីធ្វើការងារដែលភាគច្រើនជាកម្មករ។

- **កត្តាសេដ្ឋកិច្ចៈ** ភាពចាំបាច់នៃយន្តូបនីយកម្មកសិកម្ម (កសិកម្មដែលត្រូវការការប្រើប្រាស់គ្រឿងយន្ត) ភាពគ្មានដីធ្លី ឬការមានដីតិចតួច ផលចំណេញសេដ្ឋកិច្ចមិនគ្រប់គ្រាន់ ដែលទទួលបានពីសកម្មភាពកសិកម្ម ក៏ដូចជាទីផ្សារខ្សត់ខ្សោយសម្រាប់ផលិតផលកសិកម្ម បានធ្វើឲ្យប្រាក់ចំណូលរបស់អ្នកភូមិថយចុះនិងមិនទៀងទាត់ ហើយជាផលវិបាក ពួកគេចាំបាច់ត្រូវពឹងផ្អែកលើឥណទាន និង ត្រូវរិះរកវិធីផ្សេងៗដើម្បីសងបំណុល។
- **កត្តាសង្គមៈ** សម្ភារនិយម ការបញ្ចុះបញ្ចូលពីអ្នកជិតខាងនិងមេខ្យល់ មហិច្ឆិតាចង់រកប្រាក់ឲ្យបានច្រើន និង ការចង់សាងសង់/ជួសជុលផ្ទះរបស់ខ្លួនឲ្យបានល្អដូចផ្ទះអ្នកដទៃ បានជម្រុញឲ្យអ្នកភូមិជាច្រើនធ្វើចំណាកស្រុក ទោះបីជាពួកគេបានដឹងឮយ៉ាងញឹកញាប់អំពីការបោកប្រាស់របស់ឈ្មួញ ការឃាត់ខ្លួនដោយនគរបាល និង ការកេងប្រវ័ញ្ចដោយថៅហ្វាយនាយ ។ល។
- **កត្តាគ្រួសារៈ** ភារៈត្រូវរ៉ាប់រងសមាជិកគ្រួសារដែលមានជម្ងឺ ថ្លៃសិក្សាសម្រាប់កូន របស់របរប្រើប្រាស់ និង ការឧបត្ថម្ភជីវភាពគ្រួសារផ្សេងទៀត ត្រូវបានចាត់ទុកថាជាកត្តាចម្បងមួយទៀតដែលជំរុញឲ្យប្រជាជនធ្វើចំណាកស្រុក ដោយសង្ឃឹមថានឹងរកបានប្រាក់ច្រើន និង ផ្ញើប្រាក់ខ្លះត្រឡប់មកផ្ទះវិញយ៉ាងទៀងទាត់ ដោយមិនបានគិតគូច្រើនអំពីករណីអវិជ្ជមានឡើយ។





ផ្អែកលើការជួបប្រជុំមួយចំនួន ប្រជាជនក្នុងសហគមន៍បានយល់ដឹងអំពីមូលហេតុឫសគល់ខាងលើ និងបានរៀបចំផែនការសកម្មភាពមួយចំនួន ដើម្បីធ្វើសកម្មភាពរួមគ្នា ជាមធ្យោបាយមួយដើម្បីជម្រុញ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពសម្រាប់ភូមិពួកគេ។

- **តែងតាំងអ្នកទទួលបន្ទុកទំនាក់ទំនង និងចុះតាមផ្ទះប្រជាពលរដ្ឋ:** តែងតាំងអ្នកទទួលបន្ទុកទំនាក់ទំនងតាមប្រទេសគោលដៅ នៃការធ្វើចំណាកស្រុក ដែលអាចផ្តល់ព័ត៌មាន មានប្រយោជន៍ និងព័ត៌មានបញ្ជូនបន្ត។ អ្នកទទួលបន្ទុកទំនាក់ទំនងទាំងនោះក៏រៀបចំកិច្ចប្រជុំដ៏ទៀងទាត់ផងដែរជាមួយអ្នកភូមិ ជាពិសេសអ្នកដែលចាប់អារម្មណ៍លើការធ្វើចំណាកស្រុកដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្នភាពជូនពួកគេ។
- **ដំណើរការវគ្គបណ្តុះបណ្តាលអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព:** តាមរយៈកិច្ចសហការ ក្នុងចំណោមបុគ្គលិកបីរូបនៃអង្គការ HAI អាជ្ញាធរមូលដ្ឋាន តំណាងសហគមន៍ និងស្ថាប័ន ក្រសួងពាក់ព័ន្ធផ្សេងទៀត (មណ្ឌលការងារខេត្តបាត់ដំបង) ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពជូនសហគមន៍នៅក្នុងតំបន់។
- **បញ្ជ្រាបការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពទៅក្នុងកម្មវិធីនានារបស់សហគមន៍:** ដែលនៅក្នុងនោះ អ្នកជួយសម្របសម្រួលសំខាន់ៗ ដូចជាអាជ្ញាធរមូលដ្ឋាន តំណាងសហគមន៍ និងបុគ្គលិកអង្គការ HAI អាចប្រើពេលវេលាខ្លះនៃកម្មវិធីជួបជុំរបស់សហគមន៍ ដើម្បីជម្រុញការយល់ដឹងរបស់ប្រជាជនក្នុងសហគមន៍អំពីបញ្ហាចំណាកស្រុក។
- **មាតាបិតាទូន្មានកូនចៅខ្លួនអំពីការធ្វើចំណាកស្រុក:** គឺជាកិច្ចដំណើរការជាប់ជាប្រចាំជាពិសេសនៅពេលដែលមាតាបិតាបានចូលរួមក្នុងកិច្ចប្រជុំអំពីការធ្វើចំណាកស្រុក ពួកគេអាចធ្វើបច្ចុប្បន្នកម្ម/ចែករំលែកព័ត៌មាន / ទូន្មានកូនចៅខ្លួនអំពីរបៀបធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។

ការអនុវត្ត PAR គឺជាវិធីមួយដើម្បីសិក្សាពីបញ្ហាលេចឡើងរបស់សហគមន៍ និង ដើម្បីកំណត់ដំណោះស្រាយសមស្រប តាមវិធីមានការចូលរួម ត្រូវបានចាត់ទុកថាគឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយ សម្រាប់អប់រំប្រជាជន ឲ្យផ្លាស់ប្តូរផ្នត់គំនិតរបស់ខ្លួន និងចាប់ផ្តើមធ្វើសកម្មភាពរួមគ្នាដើម្បីដោះស្រាយបញ្ហារួមគ្នា។ ម្យ៉ាងទៀត ដោយសារវិធីនោះគឺជាវដ្តនៃការធ្វើសកម្មភាពមួយ ដែលអាចជម្រុញឲ្យអ្នកភូមិប្រើប្រាស់ភាពជាម្ចាស់និងភាពជាដៃគូរបស់ខ្លួនក្នុងការអភិវឌ្ឍសហគមន៍របស់ពួកគេប្រកប ដោយនិរន្តរភាពផងដែរ៕

> *"វិធីនេះគឺងាយស្រួលប្រើណាស់ អ្នកភូមិអាចទទួលយកបាន ហើយវាស្រាយបំភ្លឺនូវការយល់ឃើញមិនត្រឹមត្រូវកាលពីមុនដែលថា យើងគឺជាអ្នកដែលធ្វើ មិនមែនសហគមន៍ទេ។ តាមរយៈវិធីនេះ សហគមន៍កំណត់បញ្ហារបស់ខ្លួន និង កំណត់អាទិភាព ហើយដោះស្រាយដោយខ្លួនឯង មិនមែនទុកឲ្យអង្គការមិនមែនរដ្ឋាភិបាលដឹកនាំគ្រប់ជំហាននោះទេ"* ដោយ សំភ័ណ អង្គការជួយជនចាស់ជរាអន្តរជាតិ-កម្ពុជា (Help Age International-Cambodia (HAI))។

# លើកកម្ពស់ការថែទាំសុខភាពបឋម និងអនាម័យ នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់

ការស្រាវជ្រាវសម្របសម្រួលដោយៈ ឡី ហៀប និង ង៉ែត រិទ្ធី

បន្ទាប់ពីធ្វើការឆ្លុះបញ្ចាំងនៅសហគមន៍ដើម្បីកំណត់បញ្ហាដែលលេចឡើង ជាមួយភាគីពាក់ព័ន្ធក្នុងតំបន់ និងរួមជាមួយបទពិសោធន៍ការងាររបស់បុគ្គលិកសហគមន៍របស់អង្គការសេវាកម្មអភិវឌ្ឍន៍ជនពិការ (DDSP) នៅភូមិព្រៃក ២ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ពួកគេបានរកឃើញបញ្ហាលេចឡើងសំខាន់ៗមួយចំនួន រួមមានបញ្ហាជីវភាព អប់រំ និង ធនធានធម្មជាតិជាដើម។ ភូមិនេះមានជនពិការក្នុងបន្ទុកជាច្រើន (៧៩ នាក់ ក្នុងចំណោមប្រជាជន សរុបចំនួន ១ ១៥០ នាក់) និងកុមារ ក្នុងចំណោមគ្រួសារចំនួន ២៣៧ ហើយពួកគេភាគច្រើនរស់នៅជាក្រុមតូចៗនៅជិតតំបន់ព្រៃភ្នំ។ ពួកគេប្រើប្រាស់ទឹកក្នុងស្ទឹងពោធិ៍សាត់ និងទឹកអណ្តូងខ្លះៗ ដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលធ្វើការក្នុងតំបន់នោះ ប៉ុន្តែ កាលពីពេលមុនមិនសូវបានគិតគូពី ការអនុវត្តអនាម័យប្រចាំថ្ងៃរបស់ពួកគេ និងបញ្ហាបរិស្ថានឡើយ ហើយម្យ៉ាងវិញទៀតភ្នាក់ងារសុខភាពក៏កម្របានចុះទៅចូលរួម ផ្សព្វផ្សាយដល់តំបន់នោះ ដែរ។

មន្ត្រីអង្គការ DDSP បានចូលរួមជាមួយភាគីពាក់ព័ន្ធសំខាន់ៗក្នុងសហគមន៍ ដូចជាអាជ្ញាធរភូមិ តំណាងអង្គការក្នុងសហគមន៍ និង បុគ្គលសំខាន់ៗក្នុងភូមិផ្សេងទៀត ជាពិសេសអ្នកទទួលបន្ទុកទំនាក់ទំនងនៃក្រុមជនពិការ ដើម្បីឆ្លុះបញ្ចាំងបញ្ហានេះនិងចូលរួម ដោយប្រើប្រាស់ការស្រាវជ្រាវតាមបែបចូលរួមដើម្បីធ្វើសកម្មភាព (PAR) ដែលមានគោលបំណងសិក្សារកមូលហេតុពិតនៃបញ្ហា ផលប៉ះពាល់របស់វាលើសុខភាព និងដើម្បីរិះរកដំណោះស្រាយសមស្រប សម្រាប់រៀបចំផែនការសកម្មភាពឈានដល់ការដោះស្រាយបញ្ហានោះ។ ការស្រាវជ្រាវនេះបានធ្វើការសិក្សា យ៉ាងស្វិតស្វាញអស់រយៈពេលបួនថ្ងៃ សម្រាប់ការប្រមូលព័ត៌មាន នៅដើមខែឧសភា ឆ្នាំ២០១៣ ជាមួយការពិភាក្សាក្រុមតូចៗចំនួន ១៥ ក្រុម និង ការសម្ភាសន៍ស៊ីជម្រៅជាមួយអ្នកភូមិពាក់ព័ន្ធចំនួន ២៥ នាក់។



ប្រជាជនត្រូវបានធ្វើចលនាកៀរគរឲ្យចូលរួមក្នុងកិច្ចប្រជុំភូមិដើម្បីពិភាក្សា វិភាគ និងរៀបចំផែនការសម្រាប់ធ្វើសកម្មភាពដែលនាំទៅដល់ការដោះស្រាយបញ្ហា។ ទម្លាប់អនុវត្តមិនល្អជាច្រើនរបស់អ្នកភូមិត្រូវបានកំណត់ឡើង។ ឧទាហរណ៍ មានតែគ្រួសារមួយចំនួនតូចប៉ុណ្ណោះដែលមានបង្គន់ស្ងួត ឬបង្គន់អនាម័យដែលបានទទួលការជួយឧបត្ថម្ភមួយផ្នែក ដោយគម្រោងអង្គការមិនមែនរដ្ឋាភិបាល ហើយគ្រួសារទាំងនោះ ក៏មិនបានប្រើប្រាស់បង្គន់របស់ពួកគេឲ្យបានទៀងទាត់ឡើយ។ អ្នកភូមិស្ទើរតែទាំងអស់ប្រើទឹកពីស្ទឹងផ្ទាល់តែម្តង ហើយទោះបីជាគ្រួសារភាគច្រើនត្រូវបានផ្តល់ជូនធុងចម្រោះទឹកក្តី ក៏ពួកគេមិនបានប្រើធុងចម្រោះទាំងនោះឲ្យបានសមស្របឡើយ។ ការថែទាំប្រចាំថ្ងៃ រួមមានការចំអិនម្ហូបអាហារ ការលាងសម្អាត និងការទុកដាក់ម្ហូបអាហារ ដែលរងការប៉ះពាល់ពីសត្វចិញ្ចឹមរបស់ពួកគេ និងមានការយកចិត្តទុកដាក់តិចតួច ចំពោះបរិស្ថានប្រចាំថ្ងៃនៅជុំវិញលំនៅស្ថាន ឬការថែទាំកូនចៅពួកគេ ដូចជាការលាងសម្អាតដៃ ការបោកគក់ជាដើម។ អ្នកភូមិបានឆ្លុះបញ្ចាំងអំពីទម្លាប់មិនល្អទាំងនេះ និងបានកំណត់មូលហេតុនៃបញ្ហាសុខភាពនានា ដូចជាជម្ងឺរាគរូស ជម្ងឺគ្រុនពោះវៀន បញ្ហាក្រពះ និងជម្ងឺគ្រុនក្តៅ ។ល។ ពួកគេក៏ផ្សារភ្ជាប់បញ្ហាទៅនឹងថ្លៃចំណាយទាំងពេលវេលា និងប្រាក់កាសសម្រាប់ព្យាបាលជម្ងឺផងដែរ។ តំណាងគ្រួសារចូលរួមទាំង ៥៦ រួមមានទាំងតំណាងបីរូបនៃគណៈកម្មការ ជនពិការនៅក្នុងភូមិ និង អាជ្ញាធរភូមិបានបង្ហាញពីការយល់ដឹងដ៏តិចតួចរបស់ពួកគេ ដែលនាំឲ្យពួកគេមានបញ្ហាសុខភាពបឋម និង បានពិភាក្សាថែមទៀតអំពីមូលហេតុ ឬសគល់ដែលធ្វើឲ្យពួកគេអាចកាត់បន្ថយបញ្ហាបាន។ ជាចុងក្រោយ ពួកគេបានរៀបចំផែនការសម្រាប់រៀបចំសាងសង់បង្គន់ស្ងួត[2] សម្រាប់គ្រួសារ និងបានស្នើសុំការអប់រំបន្ថែមទៀតអំពីការថែទាំសុខភាពបឋម។

ក្នុងអំឡុងពេលតាមដានបន្តដោយ អ្នកសម្របសម្រួលការស្រាវជ្រាវ និងការឆ្លុះបញ្ចាំងជាមួយអ្នកចូលរួមក្នុងភូមិ និង អាជ្ញាធរ ក្នុងរយៈពេលពីរខែក្រោយមក យើងបានដឹងថាអ្នកភូមិបានយកចិត្តទុកដាក់បានកាន់តែប្រសើរឡើងលើការថែទាំសុខភាពបឋមរបស់ពួកគេ ក្រោយពេលដែលពួកគេបានអនុវត្តផែនការសកម្មភាព។ គ្រួសារចំនួន១៤ បានសាងសង់បង្គន់ស្ងួតរបស់ខ្លួន ហើយគ្រួសារជាច្រើនផ្សេងទៀតមានផែនការសាងសង់ ខណៈដែលគ្រួសារផ្សេងទៀត បានគិតអំពីការសាងសង់បង្គន់សម្រាប់ប្រើប្រាស់ផងដែរ។ គ្រួសារភាគច្រើន បានគិតអំពីរបៀបគ្រប់គ្រងឲ្យបានសមស្របលើការបន្ទោរបង់របស់ពួកគេ ក៏ដូចជាដើម្បីកាត់បន្ថយការបំពុលទឹកប្រើប្រាស់ពីស្ទឹង។ ផ្ទុយទៅវិញ មូលហេតុថ្មីបន្ថែមទៀត នៃការបំពុលទឹកត្រូវបានរាយការណ៍ថាបណ្តាលមកពីក្រុមហ៊ុនឯកជនមួយដែលស្ថិតនៅខ្សែទឹកខាងលើនៃដងស្ទឹង។ បន្ទាប់មក បញ្ហានេះត្រូវបានលើកយកដោយអាជ្ញាធរភូមិ សម្រាប់ធ្វើការស៊ើបអង្កេតបន្ថែមទៀត ហើយនឹងលើកយកទៅពិភាក្សានៅកម្រិតឃុំ។

[2] អ្នកភូមិមួយចំនួនបានស្នើសុំការជួយគាំទ្រមួយផ្នែកពីអង្គការមិនមែនរដ្ឋាភិបាលដើម្បីរៀបចំបង្គន់អនាម័យ ប៉ុន្តែអង្គការមិនអាចឆ្លើយតបបានដោយសារមិនមានថវិកាក្នុងគម្រោង។



អង្គការ DDSP និងជនបង្គោលសំខាន់ៗក្នុងភូមិ ក៏អាចរៀបចំឲ្យគ្រូបង្គោលមកពីឃុំ បានផ្តល់ការអប់រំខ្លះជូនអ្នកភូមិក្នុងតំន់នោះ។ គ្រួសារទាំង ២១ ដែលតំណាងប្រជាពលរដ្ឋមកពីតំបន់ផ្សេងៗក្នុងក្នុងភូមិ បានសិក្សាមិនត្រឹមតែអំពីការថែទាំសុខភាពបឋម និងអនាម័យប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបានសិក្សាអំពីការការពារសុខភាពផ្សេងទៀតផង ដូចជាជម្ងឺគ្រុនចាញ់ ការថែទាំសុខភាពមាតា និងការពន្យារកំណើត។ ផ្ទាំងរូបភាពផ្សេងៗត្រូវបានចែករំលែក និងសាកល្បងការយល់ដឹងពីអត្ថន័យរូបភាព ក្រោយពេលបណ្តុះបណ្តាល ដើម្បីធានាឲ្យបានប្រាកដថាអ្នកភូមិបានយល់ និងអាចយកសម្ភារៈទាំងនោះទៅផ្ទះ ដើម្បីស្វែងយល់ថែមទៀត និងដើម្បីជួយអប់រំអ្នកជិតខាង។

*...... អ្នកភូមិជាច្រើនមានការប្រែប្រួល ដោយពួកគេចាប់ផ្តើមលាងដៃ មុនពេលបរិភោគ ពួកគេដាំទឹកសម្រាប់ពិសា ហើយ គ្រួសារដែលមិនប្រើធុងទឹកចម្រោះបានវិលមកប្រើវិញ។ ... ពួកគេ ក៏លាងសម្អាតនិងថែទាំកូនៗ និងកន្លែងរស់នៅ [នៅជុំវិញនិងនៅក្នុងផ្ទះ]។* ការឆ្លុះបញ្ចាំងជាមួយសិក្ខាកាមមួយរូបនៃវគ្គសិក្សា CPAR នៅក្នុងភូមិ។





អ្នកចូលរួមបានឆ្លុះបញ្ចាំងថាដោយបានពិភាក្សាអំពីមូលហេតុនៃការបំពុល និងជម្ងឺក្នុងសហគមន៍ពួកគេ ពួកគេបានដឹងថាវាគឺជាបញ្ហារបស់សហគមន៍ដែលត្រូវការធ្វើសកម្មភាព និងការចូលរួមទាំងអស់គ្នា។ ស្របពេលជាមួយគ្នានោះផងដែរ សកម្មភាពពួកគេនៅមានកម្រិតនៅឡើយ ដើម្បីឲ្យសកម្មក្នុងតួនាទីទៅគៀរគរ និង ចែករំលែកអ្វីដែលពួកគេបានយល់ដល់អ្នកដទៃ។ អាស្រ័យហេតុនេះ ការជួយគាំទ្រជាបន្តពីខាងក្រៅនៅតែមានសារៈសំខាន់ដើម្បីជួយរំរុញកិច្ចដំណើរការនេះលឿនឆ្ពោះទៅមុខ។

យើងអាចសន្និដ្ឋានបានថាការយល់ដឹងតិចតួចរបស់អ្នកភូមិមូលដ្ឋាន បាននាំឲ្យមានទម្លាប់អនុវត្តប្រចាំថ្ងៃមិនល្អសម្រាប់ការពារពួកគេ និងថែទាំកូនៗកុំឲ្យឈឺ ប៉ុន្តែពួកគេអាចសម្រេចចិត្តធ្វើការផ្លាស់ប្តូរសម្រាប់ខ្លួនឯង ក្រោយពេលបានរៀនសូត្រអំពីការថែទាំសុខភាពបឋម និងវិធីការពារផ្សេងទៀត។ ពួកគេបានកោតសរសើរជាខ្លាំងចំពោះការរៀនសូត្រពីកិច្ចដំណើរការ និងបានស្នើសុំការជួយគាំទ្រនិងការសម្របសម្រួលថែមទៀត និងកំពុងពិចារណាការជួយគាំទ្រពីខាងក្រៅ ដើម្បីដោះស្រាយ

បញ្ហាផ្សេងទៀត ខណៈដែលពួកគេយល់ថាពួកគេមិនទាន់រឹងមាំគ្រប់គ្រាន់ ដើម្បីមានឥទ្ធិពលលើសហគមន៍មូលដ្ឋានពួកគេ ក៏ដូចជាផ្តោតលើជីវភាពគ្រួសារច្រើនជាង។ ការផ្សារភ្ជាប់ថែមទៀតរវាងតំណាងនៃសហគមន៍មូលដ្ឋានទៅនឹងអាជ្ញាធរផ្សេងទៀតក្រៅពីកម្រិតភូមិ ក៏មានសារៈសំខាន់ផងដែរ ដើម្បីអនុវត្តតួនាទីពាក់ព័ន្ធនេះ និងពង្រឹងសិទ្ធិអំណាចដល់ពួកគេ ដើម្បីកិច្ចដំណើរការប្រកបដោយនិរន្តរភាពសម្រាប់ដោះស្រាយបញ្ហា៕

# ប្រព័ន្ធធ្វើស្រែសម្រាប់កសិករនៅ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់

អនាគតកុមារ ANAKOT KUMAR
សហគមន៍កសាងកម្ពុជា COMMUNITY BUILD CAMBODIA

ការស្រាវជ្រាវសម្របសម្រួលដោយៈ កែ សុភា និង សឿន រ៉ាវី ជួយសម្របសម្រួលៈ ជា ស្រីនាង

*ខ្ញុំបានរៀនសូត្រច្រើនពីវគ្គសិក្សា និង បានអនុវត្តជាមួយសហគមន៍។ ជាពិសេស ក្នុងការសរសេររបាយការណ៍ស្រាវជ្រាវ ដោយសារខ្ញុំកម្រមានឱកាសបានចូលរួមវគ្គបណ្តុះបណ្តាល និង មិនដែលបានចូលរួមវគ្គសិក្សាដូចនេះទេតាំងពីមុនមក យើងបានសិក្សានិងធ្វើរួមគ្នា។ សុភា អ្នកចូលរួមវគ្គសិក្សា CPAR មួយរូប។*

ការធ្វើស្រែ គឺជារបរចិញ្ចឹមជីវិតដ៏សំខាន់ក្នុងចំណោមអ្នកភូមិមូលដ្ឋានស្ទើរតែទាំងអស់នៅក្នុងឃុំលាជ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ កសិករទាំងអស់ធ្លាប់ធ្វើស្រែរដូវវស្សាតាមបែបប្រពៃណី នៅក្បែរៗភូមិឋានរបស់ខ្លួន។ ដីស្រែក្នុងភូមិប៉ែនមានទំហំ ១៥៧.៩៩ ហិកតា ជាមួយទំហំជាមធ្យមប្រមាណជាកន្លះហិកតាសម្រាប់គ្រួសារនីមួយៗក្នុងចំណោមគ្រួសារទាំង ៣០៧។ ការមានដីស្រែតិច និង ប្រព័ន្ធធ្វើស្រែបែបប្រពៃណី នាំឲ្យមានការខ្វះខាតសម្រាប់ស្បៀងអាហារក្នុងរយៈពេលពេញមួយឆ្នាំ ព្រមទាំងបានបង្កើនថ្លៃទុនចំណាយលើការធ្វើស្រែសម្រាប់អ្នកភូមិ។ ប្រការនេះ ក្នុងឆ្នាំ២០១០ បាននាំឲ្យមានគម្រោងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតូចក្នុងតំបន់នេះដែលណែនាំឲ្យប្រើវិធីធ្វើស្រែបែបថ្មី ដែលមានបំណងបង្កើនផលិតភាពតាមរយៈប្រព័ន្ធប្រពលវប្បកម្មដាំណាំស្រូវ (SRI) នាំការយកចិត្តទុកដាក់លើរបៀបធ្វើស្រែ និងកាត់បន្ថយថ្លៃចំណាយលើផលិតកម្ម។





ការសិក្សានេះ បានអនុវត្តវិធីស្រាវជ្រាវដោយមានការចូលរួមដើម្បីធ្វើសកម្មភាព (PAR) ដែលសម្របសម្រួលដោយអង្គការអនាគតកុមារ គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយធ្វើការនៅក្នុងតំបន់នោះ ព្រមទាំងមានការចូលរួមពីប្រជាជនក្នុងសហគមន៍មូលដ្ឋាន និងភាគីអភិវឌ្ឍន៍ពាក់ព័ន្ធផ្សេងទៀត រួមមានអាជ្ញាធរមូលដ្ឋាន អ្នកអនុវត្តសាកល្បងវិធីប្រពលវប្បកម្ម (SRI)កសិករគម្រូក្នុងតំបន់ និងអ្នកអនុវត្តគម្រោងដទៃទៀតក្នុងសហគមន៍។ ពួកគេបានចូលរួមក្នុងកិច្ចដំណើរការនេះ ចាប់តាំងពីមានការឆ្លុះបញ្ចាំងអំពីបញ្ហាថ្មីនេះ រួមមានកិច្ចដំណើរការប្រមូលទិន្នន័យ ការរៀបចំ និងការអនុវត្ត

សកម្មភាព ឆ្លុះបញ្ចាំងទាញយកមេរៀនជាបទពិសោធន៍ និង ការបោះជំហានទៅមុខចេញពីកិច្ចដំណើរការចូលរួមនេះដើម្បីកែលម្អស្ថានភាពក្នុងតំបន់។ ការស្រាវជ្រាវនេះ បានពិនិត្យមើលទម្លាប់ធ្វើស្រែបច្ចុប្បន្ន បានស្វែងយល់ពីមូលហេតុ និងស្ថានភាពអំណោយផលសម្រាប់របៀបធ្វើស្រែបែបថ្មី និង ស្វែងរកវិធីដើម្បីជំរុញការធ្វើស្រែប្រកបដោយប្រសិទ្ធភាព និងកាន់តែប្រសើរក្នុងតំបន់នេះ។

## អ្នកភូមិបានរៀនសូត្រចេញពីវិធីថ្មីនៃប្រព័ន្ធធ្វើស្រែ

លទ្ធផលពីភូមិប៉ែន បានបង្ហាញថាកសិករធ្លាប់ និងពេញចិត្តជាមួយរបៀបធ្វើស្រែតាមប្រពៃណីរបស់ខ្លួនក្នុងការធ្វើស្រែវស្សា ដោយសារពួកគេមានបទពិសោធន៍អំពីការរៀបចំដី គ្រាប់ពូជ ស្ទូង និងចំណាយពេលបន្តិចបន្តួចប៉ុណ្ណោះសម្រាប់ថែទាំស្រែ។ មានប្រហែល ៣២ គ្រួសារ បានទទួលបទពិសោធន៍រួចហើយក្នុងការធ្វើស្រែដោយប្រើវិធីប្រពលវប្បកម្មដំណាំស្រូវ (SRI) ក្រោយពេលដែលពួកគេបានរៀនវិធីនេះពីភ្នាក់កសិកកម្ម និងគម្រោងអង្គការមិនមែនរដ្ឋាភិបាលក្នុងតំបន់ និង បានសាកល្បងធ្វើជាមួយផ្ទៃដីស្រែតូចៗរបស់ពួកគេ។ ពួកគេសប្បាយចិត្តចំពោះការទទួលបានផលច្រើន និងការកាត់បន្ថយថ្លៃចំណាយលើគ្រាប់ពូជ ប៉ុន្តែ មានការបារម្ភអំពីកម្លាំងពលកម្មក្នុងការរៀបចំដី ការស្ទូងការគ្រប់គ្រងទឹក និង ការថែទាំស្រែ។ ម្យ៉ាងទៀត ចំណេះដឹងពួកគេនៅមានកម្រិតនៅឡើងអំពីការប្រើវិធីប្រពលវប្បកម្ម (SRI) ហើយការសាកល្បងកាលពីឆ្នាំមុន នៅពេលដែលសន្ទូងលូតលាស់ វាក៏ជួនពេលមានការបំផ្លាញដោយកណ្ដុរពីស្រែគម្រូប្រើវិធីប្រពលវប្បកម្ម (SRI)។ ប្រការនេះបានធ្វើឲ្យពួកគេមានការរារែកក្នុងការពង្រីកប្រព័ន្ធធ្វើស្រែដោយប្រើវិធីប្រពលវប្បកម្ម (SRI) ទោះបីជាដីស្រែរបស់ពួកគេមិនសូវមានទំហំធំ និងនៅជិតភូមិ ដែលផ្ដល់ស្ថានភាពអំណោយផលខ្លាំងសម្រាប់អនុវត្តប្រព័ន្ធថ្មីនេះក្ដី។



នៅក្នុងកិច្ចប្រជុំភូមិដើម្បីពិភាក្សាអំពីរបៀបកែលម្អប្រព័ន្ធធ្វើស្រែ ក៏ដូចជាបង្កើនផលិតកម្ម អ្នកភូមិនិងភាគីពាក់ព័ន្ធផ្សេងទៀតបានឆ្លុះបញ្ចាំង អំពីបទពិសោធន៍កន្លងមករបស់ពួកគេអំពីការធ្វើស្រែបែបប្រពៃណី និង ប្រៀបធៀបទៅនឹងប្រព័ន្ធធ្វើស្រែបែបថ្មី។ ពួកគេបានខិតខំរិះរកវិធីនានាដែលធ្វើឲ្យពួកគេអាចកែលម្អការធ្វើស្រែពួកគេបានល្អ។ ជាចុងក្រោយ ពួកគេទាំងអស់គ្នាបានសម្រេចចិត្តបន្តសាកល្បងប្រើវិធីប្រពលវប្បកម្ម (SRI) ហើយពួកគេធ្វើស្រែតាមវិធីនេះនៅលើដីស្រែសមស្របរបស់ពួកគេ ដោយសារពួកគេបានដឹងថាវិធីនេះត្រូវការកម្លាំងពលកម្មសមស្របសម្រាប់ស្ទូង ហើយ

ពួកគេមិនអាចជួលកម្លាំងពលកម្មបន្ថែមដែលមានការយល់ដឹងច្រើនជាងអំពីការងារបច្ចេកទេសថ្មីនេះ។ តាមបទពិសោធន៍នៃវិធីប្រពលវប្បកម្ម (SRI) ប្រសិនបើពួកគេប្រវាសដៃគ្នា ធ្វើឲ្យពួកគេមានការបារម្ភអំពីការរកកម្លាំងព្រោះអាយុសន្ទូងរបស់ពួកគេដែលត្រូវស្ទូងក្នុងពេលដំណាលគ្នា។ បន្ទាប់មក ពួកគេបានស្នើសុំការបណ្តុះបណ្តាលបន្ថែមទៀតអំពីវិធីប្រពលវប្បកម្ម (SRI) និង ការផ្សព្វផ្សាយជូនអ្នកភូមិផ្សេងទៀតដែលមិនបានដឹង ឬមិនសូវចាប់អារម្មណ៍លើប្រព័ន្ធថ្មីនេះ។ ពួកគេក៏បានស្នើសុំធ្វើទស្សនកិច្ចសិក្សាផងដែរ ដើម្បីទទួលបានបទពិសោធន៍ជាក់ស្តែងពីតំបន់ផ្សេងទៀតដែលបានអនុវត្តវិធីប្រពលវប្បកម្ម (SRI) ប្រកបដោយជោគជ័យ។ សំណើពីរដំបូងត្រូវបានរៀបចំទៅជាផែនការសកម្មភាពច្បាស់លាស់ ខណៈពេលសំណើទីបីកំពុងរង់ចាំរហូតដល់ពេលពួកគេរកឃើញមធ្យោបាយមួយដើម្បីគាំទ្រសកម្មភាពនេះ។

*ខ្ញុំយល់ថាវិធីដែលបានរៀនពីវគ្គបណ្តុះបណ្តាលគឺ មានប្រយោជន៍ណាស់ សម្រាប់ពួកយើង។ យើងអាចប្រើវានៅក្នុងស្រែយើង ប៉ុន្តែវាមានលក្ខណៈថ្មី [របៀបថ្មីនៃការធ្វើស្រែ] ហើយយើងមិនមានកម្លាំងពលកម្មគ្រប់គ្រាន់ដោយគ្រួសារតូច។ យើងដាំស្រូវក្នុងស្រែដ៏តូចរបស់យើង។ [ជាបទពិសោធន៍] ផលិតផលឆ្នាំមុនគឺបានច្រើនធៀបទៅនឹងស្រែវស្សាបែបប្រពៃណី។ សិក្ខាកាមមួយរូបក្នុងចំណោមសិក្ខាកាមក្នុងភូមិ លាជ ដែលបានអនុវត្តវិធីប្រពលវប្បកម្ម (SRI)។*

ក្នុងរដូវធ្វើស្រែវស្សា អ្នកភូមិ ដែលចាប់អារម្មណ៍លើវិធីប្រពលវប្បកម្ម (SRI) ចាប់តាំងពីកិច្ចប្រជុំភូមិ បានកំណត់នូវភាពចាំបាច់ត្រូវចាប់ផ្តើមអនុវត្តវិធីនានា ដូចជាការរៀបចំដីនិងសំណាបក្នុងខែ មិថុនា។ ជាលទ្ធផល អ្នកភូមិចំនួន ១៤ នាក់បានបន្តអនុវត្តវិធីប្រពលវប្បកម្ម (SRI) ហើយបន្ទាប់មកការបណ្តុះបណ្តាលបន្ថែមអំពីវិធីប្រពលវប្បកម្ម (SRI) ត្រូវបានធ្វើដោយជំនាញការមួយរូប មកពីអង្គការអនាគតកុមារ ដោយហេតុតែពួកគេមិនអាចទាក់ទងរកជំនាញការកសិកម្មបានក្នុងពេលដែលសមស្រប។ អ្នកភូមិដែលបានចូលរួមសិក្សា បានរៀនសូត្រថែមទៀតអំពីវិធីនេះ និង អាចបំភ្លឺចំណុចខ្លះដែលពួកគេមិនបានយល់ច្បាស់ ដូចជាប្រភេទពូជសមស្រប ការគ្រប់គ្រងទឹក ។ល។ និង ។ល។ ពួកគេក៏បានពិភាក្សានិងចែករំលែកផងដែរនូវបទពិសោធន៍ផ្ទាល់ខ្លួនពួកគេ ដើម្បីធ្វើស្រែតាមវិធីប្រពលវប្បកម្ម (SRI) ឲ្យបានកាន់តែប្រសើរឡើងក្នុងតំបន់។

ក្រោយពេលបញ្ចប់វដ្តនៃកិច្ចដំណើរការស្រាវជ្រាវដោយមានការចូលរួម ដើម្បីធ្វើសកម្មភាព (PAR) ការឆ្លុះបញ្ចាំងរបស់អ្នកចូលរួមអាចកំណត់បាននូវមេរៀនជាបទពិសោធន៍មួយចំនួនដែលបានរៀនសូត្រសម្រាប់ការយល់ដឹងនិងពីការអនុវត្តរបស់ពួកគេ។ ពួកគេកោតសរសើរចំពោះវិធីថ្មីសម្រាប់ការធ្វើស្រែ និង អាចមានការសម្របខ្លះដើម្បីយកទៅកែលម្អវិធីបែបប្រពៃណីរបស់ពួកគេផងដែរ ខណៈ

ដែលពួកគេទើបតែចាប់ផ្តើមអនុវត្តវិធីប្រពលវប្បកម្ម (SRI) លើដីស្រែតូចៗ។ ម្យ៉ាងទៀត សិក្ខាកាម ដែលបានដឹកនាំ ការសម្របសម្រួលក្នុងកិច្ចដំណើរការនេះ បានដឹងថាវិធីស្រាវជ្រាវដោយមានការចូលរួម ដើម្បីធ្វើសកម្មភាព គឺជាឧបករណ៍មានប្រយោជន៍មួយសម្រាប់រិះរកមើលបញ្ហា និង គៀងគរប្រជាជនក្នុងសហគមន៍ឲ្យចូលរួមក្នុងដំណើរការដើម្បីដោះស្រាយ និងរៀនសូត្រពីបញ្ហារបស់ពួកគេ។ ប៉ុន្តែ គេត្រូវការពេលវេលាដើម្បីយល់ពីអត្ថប្រយោជន៍នៃប្រព័ន្ធថ្មីមួយ ការសម្របសម្រួលពីអ្នកគាំទ្រពីក្រៅដើម្បីនាំឲ្យមានការចូលរួម និង មានឆន្ទៈរៀនសូត្រពីកិច្ចដំណើរការ ខណៈដែលអ្នកភូមិ ជាទូទៅគិតគូរច្រើនជាងអំពីគ្រួសារនិងជីវភាពរបស់ពួកគេ៕

# ចលនាការចូលរួមលើកកម្ពស់ការថែទាំសុខុមាលភាពសហគមន៍ នៅស្រុកអូររាំងឪ ខេត្តកំពង់ចាម

ការស្រាវជ្រាវសម្របសម្រួលដោយៈ ហ៊ឹង សុជាវីន និង ផន សុធា

ភូមិថ្មីមានទីតាំងស្ថិតនៅក្នុងឃុំទួលសុភី ស្រុកអូររាំងឪ ខេត្តកំពង់ចាម។ ចំនួនប្រជាជនគឺ ៣៨៤ នាក់ ដែលនៅក្នុងនោះ ២៤០ នាក់គឺជាស្ត្រី (៩២ គ្រួសារ)។ អ្នកភូមិប្រហែល ៩០% គឺជាកសិករដែលមានដីស្រែតិចតួច និងរកបានប្រាក់ចំណូលទាបពីការលក់ស្រូវរបស់ខ្លួន។ កន្លងមក អ្នកភូមិភាគច្រើនបានបន្ទោបង់ដោយមិនមានប្រើបង្គន់ ហើយចំណេះដឹងពួកគាត់ អំពីការថែទាំសុខភាពបឋមគឺនៅមានកម្រិត។ ការសិក្សានេះសំដៅស្វែងយល់ពីឥរិយាបថរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ក្នុងការបន្ទោបង់ក្រៅបង្គន់ និងព្យាយាមស្វែងយល់អំពីផលប៉ះពាល់ ព្រមទាំង បង្កើនការចូលរួមរបស់សហគមន៍ដើម្បីជំរុញឲ្យមានការយកចិត្តទុកដាក់លើការថែទាំសុខភាពតាមរយៈការដោះស្រាយបញ្ហារួមគ្នា។ ការសិក្សាបានធ្វើឡើងដោយប្រើវិធីសាស្ត្រសិក្សាស្រាវជ្រាវតាមបែបចូលរួមដើម្បីសកម្មភាព(PAR) ដែលត្រូវបានសម្របសម្រួលដោយអង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម ដែលជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយធ្វើការនៅក្នុងតំបន់នេះ។ ការសិក្សានេះ មានការចូលរួមពីប្រជាពលរដ្ឋក្នុងសហគមន៍ និង ភាគីអភិវឌ្ឍន៍ពាក់ព័ន្ធផ្សេងទៀត រួមមានប្រធានភូមិ និង អ្នកទទួលបន្ទុកទំនាក់ទំនងសំខាន់ៗ។ ពួកគេបានចូលរួមក្នុងកិច្ចដំណើរការនេះតាំងពីដំណាក់កាលដំបូងរហូតដល់ចប់ដែលរួមមានការឆ្លុះបញ្ចាំង ដើម្បីកំណត់បញ្ហា ប្រមូល និងវិភាគទិន្នន័យ រៀបចំ និងអនុវត្តសកម្មភាព ឆ្លុះបញ្ចាំងអំពីមេរៀនជាបទពិសោធន៍ដែលបានទទួល និង វិធីឆ្ពោះទៅមុខដើម្បីកែលម្អស្ថានភាពក្នុងភូមិ។

## មូលហេតុដែលប៉ះពាល់ការថែទាំសុខភាព

បញ្ហាដែលកើតឡើងក្នុងភូមិនេះ ប៉ះពាល់សុខភាពគ្រួសារ ក៏ដូចជាសុខភាពក្នុងភូមិទាំងមូល។ កត្តាប៉ះពាល់សុខភាពគ្រួសារ គឺថាស្ត្រីពេញវ័យមានការលំបាកក្នុងការបន្ទោបង់ ដោយមិនមានបង្គន់។ ម្យ៉ាងទៀត មនុស្សចាស់មានជម្ងឺពិបាកក្នុងការបន្ទោបង់នៅពេលយប់ ជាពិសេស ក្នុងរដូវភ្លៀង។ លើសពីនេះទៅទៀត នៅពេលដែលគ្រួសារមួយរៀបចំពិធីអាពាហ៍ពិពាហ៍ ឬ ពិធីអ្វីមួយ ពួកគេមិនមានបន្ទប់ទឹក ឬ បង្គន់សម្រាប់ឲ្យបងប្អូន ឬភ្ញៀវប្រើប្រាស់នោះឡើយ ដែលជាហេតុនាំឲ្យមានការបន្ទោបង់ពាសវាលពាសកាល ហើយក្លិនស្អុយក៏បានលេចឡើងពាសពេញភូមិ។

ចំពោះសហគមន៍វិញ ក្លិនមិនល្អបានជះនៅជុំវិញភូមិពួកគេ ហើយជួនកាល វាបានក្លាយជាវិវាទក្នុងចំណោមអ្នកជិតខាងពួកគេ ដោយសារការបន្ទោបង់លើដីរបស់ពួកគេ។ ដោយឆ្លុះបញ្ចាំង និង

សង្កេតឃើញបញ្ហានេះ និង ដោយសារភូមិនេះគឺជាភូមិមួយនៃតំបន់គោលដៅរបស់អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម បុគ្គលិកពួកគេក៏បានរៀបចំសំណើមួយសម្រាប់ធ្វើការស្រាវជ្រាវជាផ្នែកមួយនៃការចូលរួមវគ្គសិក្សាដើម្បីដោះស្រាយបញ្ហា។

## ការផ្លាស់ប្តូរឥរិយាបថរបស់អ្នកភូមិ

ក្រោយពេលប្រមូលទិន្នន័យ កិច្ចប្រជុំភូមិត្រូវបានធ្វើដើម្បីចែករំលែក និង ពិភាក្សារបកគំហើញនៃការស្រាវជ្រាវ ពិភាក្សាបន្ថែមទៀតអំពីបញ្ហានិងមូលហេតុ និងបន្ទាប់មក ឯកភាពគ្នាលើផែនការមួយដើម្បីកែលម្អស្ថានភាពនេះ។ មានគ្រួសារចំនួន ៣៦ ដែលបានចូលរួមកិច្ចប្រជុំនេះ រួមមានអ្នកភូមិ ប្រធានភូមិ និងអ្នកទទួលបន្ទុកទំនាក់ទំនង។ របកគំហើញគួរឲ្យចាប់អារម្មណ៍បំផុតដោយការប្រើឧបករណ៍ ការសិក្សាស្រាវជ្រាវដោយមានការចូលរួមដើម្បីធ្វើសកម្មភាព (PAR) និង ការចូលរួមដ៏សកម្មពីអ្នកភូមិ បានរកឃើញនូវបញ្ហាសំខាន់ៗមួយចំនួនដូចជា អ្នកភូមិមានទម្លាប់បន្ទោបង់ដោយមិនមានប្រើបង្គន់ ដោយសារតែតំបន់នេះមានភូមិសាស្ត្រអំណោយផល អ្នកភូមិចង់បានបង្គន់ដែលទំនើបនិងទម្លាប់នៃការពឹងអាស្រ័យលើ ការជួយពីអ្នកដទៃរបស់អ្នកភូមិដែលធ្វើឲ្យតំបន់នេះនៅតែមានបញ្ហា។ ចេញអំពីកិច្ចពិភាក្សាយ៉ាងផុលផុស ពួកគេបានឯកភាពគ្នាលើកជាផែនការសកម្មភាពដើម្បីសាងសង់បង្គន់ស្ងួត ឬ បង្គន់ចាក់ទឹក ដែលអាចធ្វើបានដោយប្រើប្រាស់ធនធានជុំវិញផ្ទះ។ ក្នុងផែនការនេះ ជនបង្គោលនិងប្រធានភូមិ ចាំបាច់ត្រូវចរចា/ពិភាក្សាជាមួយអាជីវករដែលលក់សម្ភារះសម្រាប់សាងសង់បង្គន់ចាក់ទឹក ដើម្បីឲ្យមានការបង់ប្រាក់រំលោះ និងបន្ទាប់មកត្រូវប្រាប់អ្នកភូមិអំពីលទ្ធផល។ ក្រោយពេលចរចា អាជីវករបានយល់ព្រមលើការបង់រំលោះ តែតម្លៃបង់រំលោះច្រើនជាង ពីតម្លៃបង់ផ្តាច់សំរាប់បង្គន់មួយដែលអ្នកភូមិអាចទទួលយកបាន ដែលជាហេតុនាំឲ្យ អ្នកភូមិងាកមកប្រើប្រាស់ធនធានដែលពួកគេមាននៅក្នុងមូលដ្ឋានដើម្បីសាងសង់បង្គន់ចាក់ទឹក។ ម្យ៉ាងទៀត អ្នកភូមិបានស្នើសុំឲ្យបុគ្គលិកនៃអង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម រៀបចំបើកវគ្គបណ្តុះបណ្តាលមួយអំពី "បង្គន់ស្ងួត និង អនាម័យ"។

*ខ្ញុំតែងជួយអ្នកភូមិដែលមានបញ្ហា ហើយដៃគូរបស់ប្រធានភូមិក្នុងការជួយអ្នកភូមិ ដើម្បីទាក់ទងអាជីវករលក់សម្ភារះបង្គន់។ ទាក់ទិននឹងបង្គន់ចាក់ទឹក ខ្ញុំមានបង្គន់ចាក់ទឹកពីរក្នុងផ្ទះខ្ញុំ, ខ្ញុំចែករំលែកបង្គន់ចាក់ទឹកជាមួយអ្នកជិតខាងដែលជួនការត្រូវការបន្ទោបង់។ ម្យ៉ាងទៀត ខ្ញុំតែងតែចែករំលែកចំណេះដឹង បទពិសោធន៍អំពីការថែទាំ សុខភាពគ្រួសារបឋម។ ...PAR គឺមានប្រយោជន៍ណាស់សម្រាប់ប្រជាជនក្នុងសហគមន៍នេះ ដើម្បីយល់ដឹងអំពីអនាម័យ និង ខិតខំប្រើធនធានក្នុងស្រុករបស់ខ្លួនដើម្បីសាងសង់បង្គន់ស្ងួត ឬបង្គន់ចាក់ទឹកសម្រាប់ថែទាំសុខភាពគ្រួសារពួកគេ។រិនអ្នកភូមិមួយរូបក្នុងភូមិ។*



## ធនធានដែលមានស្រាប់នៅក្នុងមូលដ្ឋាននិង បង្គន់ស្ងួត

បីខែក្រោយមក ក្រោយពេលអនុវត្តផែនការសកម្មភាពនេះ អ្នកភូមិបានផ្លាស់ប្តូរទស្សនៈរបស់ខ្លួន។ កាលពីមុន អ្នកភូមិបានគិតថាការប្រើបង្គន់ស្ងួតគឺមិនល្អទេ ដោយសារវានៅតែមានក្លិនអាក្រក់ និង ត្រូវចំណាយប្រាក់ច្រើនដើម្បីសាងសង់។ ប៉ុន្តែ ពួកគេបានបោះបង់គំនិតនេះចោល ហើយគ្រួសារមួយចំនួនបានសាងសង់បង្គន់ស្ងួតរួចហើយ ដោយចំណាយអស់ប្រាក់តិចតួច ដោយសារពួកគេបានប្រើធនធានក្នុងមូលដ្ឋាន។ ផ្អែកលើការតាមដានរបស់ក្រុមសម្របសម្រួល មានគ្រួសារជាច្រើនបានប្តេជ្ញាបន្តប្រើធនធានមូលដ្ឋានមានស្រាប់ដើម្បីសាងសង់បង្គន់ស្ងួត ឬ បង្គន់ចាក់ទឹក៕

*"ខ្ញុំរីករាយណាស់ដោយបានចូលរួមសិក្ខាវគ្គCPAR ដែលរៀបចំដោយ CCC។ ខ្ញុំចាប់អារម្មណ៍ខ្លាំងលើមេរៀនដែលខ្ញុំបានសិក្សាក្នុងថ្នាក់។ ចំពោះការអនុវត្តជាក់ស្តែងនៃវគ្គសិក្សា វាមានប្រយោជន៍ណាស់សម្រាប់សហគមន៍ ជាពិសេស សម្រាប់អ្នកភូមិនៅភូមិថ្មី។ វាអាចជួយឲ្យអ្នកភូមិយល់ពីការថែទាំសុខភាព ដោយបន្ទោបង់ក្នុងបង្គន់ស្ងួត ឬ បង្គន់ចាក់ទឹក និង ផ្លាស់ប្តូរឥរិយាបថរបស់ពួកគេ។ ម្យ៉ាងទៀត អង្គការ BSDA នឹងប្រើរបាយការណ៍នេះធ្វើជាមូលដ្ឋានសម្រាប់សរសេរសំណើ [គម្រោងអង្គការមិនមែនរដ្ឋាភិបាល]។"*

សុជាវីន បុគ្គលិកអង្គការសកម្មភាពពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម។

# ប្រជាសហគមន៍ចូលរួមលើកកម្ពស់អនាម័យ និង សុខភាពបឋម នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម

ការស្រាវជ្រាវសម្របសម្រួលដោយ: យីន សម័យ និង សេង សុធារិទ្ធ

*"តាងនាមឲ្យអង្គការអ្នកអភិវឌ្ឍសហគមន៍ ខ្ញុំសូមអរគុណCCC យ៉ាងច្រើន ដែលបានជ្រើសរើសរូបខ្ញុំឲ្យចូលរួមក្នុងវគ្គសិក្សា(CPAR)។ ខ្ញុំបានទទួលចំណេះដឹងដ៏ល្អពីវិធីសាស្ត្រស្រាវជ្រាវដោយមានការចូលរួមដើម្បីសកម្មភាពហើយខ្ញុំនឹងប្រើប្រាស់វិធីនេះក្នុងគម្រោងរបស់ខ្ញុំ។ បុគ្គលិក CCC បានផ្តល់កិច្ចសហការប្រសើរបំផុត និង បានរៀបចំទីកន្លែងល្អបំផុតសម្រាប់សិក្ខាកាម។ ហេតុដូច្នេះ ខ្ញុំសង្ឃឹមថាខ្ញុំនឹងមានឱកាសជាថ្មីទៀតដើម្បីបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងទៀត ដែលរៀបចំដោយ CCC។"* សម័យ សិក្ខាកាមពីអង្គការអ្នកអភិវឌ្ឍសហគមន៍ ។



ការថែទាំសុខភាពបឋម និងអនាម័យបានក្លាយជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ នៅភូមិតាំងគោក ឃុំល្វា ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ ក្នុងភូមិនេះមានប្រហែល ១៥៧ គ្រួសារ ជាមួយចំនួនប្រជាពលរដ្ឋ សរុប ៥៤៧ នាក់ ដែលនៅក្នុងនោះ ២៩១ នាក់គឺជាស្ត្រី។ កាលពីពេលមុន អ្នកភូមិភាគច្រើនមិនខ្វល់អំពីសុខភាពបឋមនិងអនាម័យ ដូចជាបន្ទោបង់ដោយមិនប្រើបង្គន់ មិនបានលាងដៃឲ្យបានត្រឹមត្រូវក្រោយពេលបន្ទោបង់ ឬមុនពេលបរិភោគ និងមិនយកចិត្តទុកដាក់ផឹកទឹកស្អាត ឬទឹកមានសុវត្ថិភាពឡើយ។

បញ្ហាទាំងនេះធ្វើឲ្យមានផលវិបាកច្រើនលើសុខភាពអ្នកភូមិ គ្រួសារ ក៏ដូចជាសហគមន៍។ ជាក់ស្តែង ពួកគេធ្លាក់ខ្លួនឈឺ ចំណាយអស់ប្រាក់ច្រើនសម្រាប់ការព្យាបាល កាត់បន្ថយភាពវៃឆ្លាតរបស់កុមារ ខាតបង់ពេលវេលារកស៊ី និង ជំពាក់បំណុល។ អង្គការអ្នកអភិវឌ្ឍសហគមន៍ បានចាប់ផ្តើមគម្រោងមួយ មានឈ្មោះថា "កែលម្អអនាម័យសហគមន៍ជនបទ" នៅដើមឆ្នាំ ២០១៣ ប៉ុន្តែ គម្រោងនោះមិនបានទទួលជោគជ័យខ្លាំងទេ ដោយសារបញ្ហាសេសសល់មួយចំនួន នៅតែកើតឡើងក្នុងភូមិរួមមាន៖ អ្នកភូមិមួយចំនួននៅតែមានជម្ងឺរាគ ក្អួត និងគ្រុនក្តៅ។

ក្នុងន័យនេះ ការសិក្សានេះសំដៅស្វែងយល់ពីមូលហេតុឫសគល់នៃបញ្ហា ស្វែងយល់ពីបទពិសោធន៍ និងផលប៉ះពាល់ផ្សេងទៀត និងស្វែងរកកិច្ចសហការដើម្បីដោះស្រាយបញ្ហាទាំងនេះ។

ការសិក្សាបានអនុវត្តវិធីសាស្ត្រ សិក្សាស្រាវជ្រាវដោយមានការចូលរួមដើម្បីធ្វើសកម្មភាព (PAR) ដែលត្រូវបានសម្របសម្រួលដោយអង្គការ អ្នកអភិវឌ្ឍសហគមន៍ ដោយមានការចូលរួមពីប្រជាជនក្នុងសហគមន៍មូលដ្ឋាន និងភាគីអភិវឌ្ឍន៍ពាក់ព័ន្ធផ្សេងទៀត រួមមានប្រធានភូមិ ក្រុមប្រឹក្សាឃុំ បុគ្គលិកអង្គការអ្នកអភិវឌ្ឍសហគមន៍ និង បុគ្គលសំខាន់ៗផ្សេងទៀត។ ភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងកិច្ចដំណើរការនៃការឆ្លុះបញ្ចាំង ការប្រមូលទិន្នន័យ ការរៀបចំផែនការសកម្មភាព និង ការអនុវត្តផែនការសកម្មភាព។

 

កិច្ចប្រជុំភូមិជាមួយអ្នកចូលរួមសរុបចំនួន ៣៥ នាក់ ត្រូវបានរៀបចំធ្វើ ដើម្បីចែករំលែក និងពិភាក្សារបកគំហើញនៃការស្រាវជ្រាវ ពិភាក្សាបន្ថែមទៀតអំពីបញ្ហានិងមូលហេតុ ហើយបន្ទាប់មកឯកភាពគ្នាលើផែនការមួយដើម្បីកែលម្អស្ថានភាព។ របកគំហើញសំខាន់ៗ បានបង្ហាញថាភូមិនេះមិនមានទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃទេ។ ប្រជាជនមិនទម្លាប់អនុវត្តអនាម័យល្អឡើយ ដូចជា ផឹកទឹកមិនស្អាត ឬ ទឹកគ្មានសុវត្ថិភាព ហូបបន្លែឆៅដោយមិនមានលាងសម្អាតបានសមស្រប មិនមានលាងដៃក្រោយពេលបន្ទោបង់ ឬមុនពេលបរិភោគអាហារ។ ក្រោយពេលកិច្ចប្រជុំ អ្នកតំណាង និងគណៈកម្មការដែលបានបង្កើត បានសម្រេចរៀបចំសកម្មភាពនានា ដែលរួមមាន៖ បង្កើតទិវាលាងសម្អាតដៃ ដើម្បីជំរុញឲ្យអ្នកភូមិមូលដ្ឋានយកចិត្តទុកដាក់លើបញ្ហានេះ ផឹកទឹកស្អាត ឬទឹកមានសុវត្ថិភាព បរិភោគអាហារមានអនាម័យប្រចាំថ្ងៃ និង លាងសម្អាតដៃឲ្យបានត្រឹមត្រូវ។ បន្ថែមលើនេះ គណៈកម្មការសំរាប់តាមដាន ការផឹកទឹកមានសុវត្ថិភាព និងលាងសម្អាតដៃត្រូវបានបង្កើតផងដែរ ដើម្បីអោយមានការអនុវត្តក្នុងសហគមន៍កាន់តែប្រសើរឡើង។

## ការរស់នៅប្រកបដោយសុខភាពល្អ

បីខែក្រោយមក នៅក្នុងការឆ្លុះបញ្ចាំងជាមួយបុគ្គលិកនៃអង្គការអ្នកអភិវឌ្ឍសហគមន៍ និងអ្នកភូមិមួយចំនួន ពួកគេបានមើលឃើញថាប្រជាជនមានការយល់ដឹង អំពីទម្លាប់អនុវត្តអនាម័យមានការកែលម្អ ក្រោយពេលពួកគេ បានចូលរួមធ្វើសកម្មភាព និងបានរៀនសូត្រពីកិច្ចដំណើរការ។ លើសពីនេះទៀត បញ្ជីតាមដានដែលសម្របសម្រួលដោយអាជ្ញាធរភូមិ និងគណ:កម្មការដែលបានបង្កើត បានបង្ហាញថាអ្នកភូមិជាច្រើនបានបរិភោគទឹកដាំពុះ។ អ្នកភូមិក៏បានសង្កេតឃើញផងដែរថាមានការថយចុះ នៃជម្ងឺមួយចំនួន។ ដោយបានចូលរួមក្នុងដំណើរការសកម្មភាពនេះ ពួកគេបានប្រែប្រួលឥរិយាបថកាន់តែប្រសើរឡើង ហើយបុគ្គលិកពីអង្គការអ្នកអភិវឌ្ឍសហគមន៍ក៏បានសម្តែងការប្តេជ្ញាខ្ពស់របស់ខ្លួនផងដែរថានឹងអនុវត្តផែនការសកម្មភាពមានស្រាប់នេះ និងបន្តសម្របសម្រួលការយល់ដឹងរបស់អ្នកភូមិ ដើម្បីអនុវត្តអនាម័យល្អ របស់ប្រជាជនក្នុងសហគមន៍៕

*"ខ្ញុំសូមអរគុណអង្គការ អ្នកអភិវឌ្ឍសហគមន៍ ដែលបានជ្រើសរើសយកភូមិខ្ញុំធ្វើជាតំបន់គោលដៅសម្រាប់រកមើលបញ្ហាថ្មីៗរបស់អ្នកភូមិ និង ដោះស្រាយបញ្ហាទាំងនោះ រួមគ្នា លើបញ្ហាសុខភាពបឋម។ ក្រោយពេលដោះស្រាយបញ្ហា ខ្ញុំបានអនុវត្តអនាម័យ ដូចជាផឹកទឹកមានសុវត្ថិភាព លាងដៃជាមួយសាប៊ូក្រោយពេលបន្ទោបង់ និង មុនពេលបរិភោគ និងបន្ទោបង់ក្នុងបង្គន់"* ច្រឹប អ្នកភូមិម្នាក់។

# ការចូលរួមលើកកម្ពស់វិស័យអប់រំនៅសាលាបឋមសិក្សាជនបទ

ការស្រាវជ្រាវសម្របសម្រួលដោយៈ ស៊ុម ផាន់នី និង ស្រួយ វ៉ាន់ស៊ី

ភូមិប៉ោយរំដែ ក្នុងឃុំរោងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង មានលក្ខណៈដាច់ស្រយាលខ្លាំង និង នៅឆ្ងាយពីផ្លូវធំ ដែលធ្វើឲ្យគ្រូបង្រៀនមានការលំបាកក្នុងការធ្វើដំណើរទៅធ្វើការរៀងរាល់ថ្ងៃក្នុងរដូវវស្សា ហើយគ្រូបង្រៀនជាច្រើន មិនមានឆន្ទៈធ្វើដំណើរក្នុងស្ថានភាពទាំងនេះទេ។ សម្រាប់សិស្សការបោះបង់ចោលការសិក្សាហាក់បីដូចជារឿងសមហេតុសមផលដោយពុំសូវមានកង្វល់។ សិស្សភាគច្រើនគឺជាកូនកសិករ ដែលឪពុកម្តាយពួកគេត្រូវធ្វើដំណើរផ្លូវឆ្ងាយរៀងរាល់ព្រឹកទៅវាលស្រែ និងមិនសូវមានពេលដើម្បីជួយគាំទ្រកូនៗពួកគេនៅពេលយប់ទេ។ មានឪពុកម្តាយសិស្សតិចណាស់ដែលមានការអប់រំក្នុងប្រព័ន្ធ។ ពុំមានគ្រូជំនាញក្នុងភូមិទេ ហើយគ្រូដែលល្អបំផុតមកពីខាងក្រៅម្នាក់អាចបង្រៀនពីរថ្នាក់នៅក្នុងបន្ទប់ តូចៗពីរ នៅសាលារៀន។ ក្នុងន័យនេះ ការសិក្សាស្រាវជ្រាវនឹងស្វែងយល់ពីមូលហេតុ ឫសគល់នៃការបោះបង់ការសិក្សា និង ចលនាប្រជាពលរដ្ឋ ក្នុងសហគមន៍ឲ្យដោះស្រាយបញ្ហានេះ។ ការសិក្សា ស្រាវជ្រាវដោយមានការចូលរួមដើម្បីធ្វើសកម្មភាព (PAR) ដែលត្រូវបានសម្របសម្រួលដោយអង្គការ RDA គឺជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលធ្វើការក្នុងតំបន់នេះដោយមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ក្នុងសហគមន៍មូលដ្ឋាន និង ភាគីអភិវឌ្ឍន៍ពាក់ព័ន្ធផ្សេងទៀត រួមមានអនុប្រធានភូមិ គ្រូបង្រៀន នាយករងសាលា និង បុគ្គលសំខាន់ៗផ្សេងទៀត។ ពួកគេបានចូលរួមក្នុងកិច្ចដំណើរការនេះ តាំងពីការឆ្លុះបញ្ចាំងអំពីបញ្ហាដែលលេចឡើង ដំណើរការប្រមូលទិន្នន័យ ការរៀបចំ និងការអនុវត្តសកម្មភាព និង ការឆ្លុះបញ្ចាំងអំពីមេរៀនជាបទពិសោធ៍ និងដំណើរការទៅមុខសម្រាប់ការរៀនសូត្ររបស់ពួកគេពីកិច្ចដំណើរការចូលរួមនេះ ដើម្បីកែលម្អស្ថានភាពក្នុងតំបន់។







លទ្ធផលពីភូមិប៉ោយរំដែបង្ហាញថា មូលហេតុឫសគល់នៃការបោះបង់ការសិក្សា មានទាក់ទិននឹងភាគីពាក់ព័ន្ធបួន។ មូលហេតុទីមួយគឺមាតាបិតាសិស្ស ដែលមិនមានពេលវេលាច្រើន សម្រាប់បង្រៀនកូននៅផ្ទះ ធ្វើចំណាកស្រុកទៅប្រទេសថៃ មិនចេះអាននិងសរសេរ មិនដែលបានតាមដានមើលការសិក្សារបស់កូន និងពុំមានទំនាក់ទំនងជាមួយមាតាបិតាសិស្ស។ មូលហេតុទីពីរ គឺគ្រូបង្រៀន ដែលមិនមានពេលច្រើន សម្រាប់បង្រៀនសិស្ស ជាពិសេស ក្នុងរដូវវស្សា ដោយសារផ្លូវពិបាកធ្វើដំណើរ។ ដោយសារការលំបាកធ្វើដំណើរទៅក្នុង និងនៅជុំវិញភូមិក្នុងរដូវវស្សា កាលពីមុនវាគឺជារឿងធម្មតា ដែលគ្រូបង្រៀនទៅដល់សាលា ប៉ុន្តែ មិនមានសិស្ស ឬសិស្សទៅដល់សាលា ប៉ុន្តែ មិនមានគ្រូបង្រៀន ដូច្នោះហើយ ក៏មានការបោះបង់ និងត្រឡប់ទៅផ្ទះវិញ។ មូលហេតុទីបី គឺសិស្ស ដែលពួកគេមិនមានការតាំងចិត្តខ្ពស់ អំពើហិង្សាក្នុងគ្រួសារ និង គ្រួសារក្រីក្រ និង ឧស្សាហ៍គេចសាលា។ មូលហេតុទីបួន គឺសង្គម។ សង្គមមិនមានសុវត្ថិភាព និងគំរូគ្រប់គ្រាន់។ ជាមួយរបកគំហើញទាំងនេះ អង្គការ RDA បានរៀបចំកិច្ចប្រជុំភូមិមួយដើម្បីចែករំលែកនិងពិភាក្សាលទ្ធផល និងដើម្បីពិចារណាវិធីនានាដើម្បីបង្កើនការយល់ដឹងក្នុងចំណោមមាតាបិតាសិស្ស និងអ្នកភូមិផ្សេងទៀត អំពីសារៈសំខាន់នៃការអប់រំ។ មាតាបិតាសិស្ស អាជ្ញាធរមូលដ្ឋាន និងអ្នកភូមិពាក់ព័ន្ធ បានមកជួបជុំគ្នាដើម្បីរៀបចំ ផែនការសកម្មភាពលម្អិតមួយ។ កិច្ចប្រជុំបានស្នើឲ្យមានការប្រជុំ រវាងមាតាបិតាសិស្ស និងគ្រូបង្រៀន រាល់ពីរខែម្តង ដើម្បីតាមដានមើលការវិវឌ្ឍរបស់សិស្ស។ រាល់អវត្តមានរបស់គ្រូបង្រៀនត្រូវបានជូនដំណឹង ដល់មាតាបិតា សិស្សជាអ្នកភូមិ។ មាតាបិតាសិស្សត្រូវបានលើកទឹកចិត្តឲ្យជួយ បង្រៀនកូនខ្លួននៅផ្ទះ។



## ឪពុកម្ដាយ និងគ្រូបង្រៀនយកចិត្តទុកដាក់អំពីការទទួលខុសត្រូវរបស់ពួកគេពីបញ្ហាអប់រំ

ការសិក្សាស្រាវជ្រាវដោយមាន ការចូលរួមដើម្បីធ្វើសកម្មភាព (PAR) បានជួយបង្កើតការគោរពថ្មីមួយចំពោះគុណតម្លៃនៃការអប់រំនៅក្នុងភូមិប៉ោយរំដែ។ លទ្ធផលមួយ គឺការទទួលស្គាល់ដ៏ទូលាយអំពីបញ្ហាបោះបង់ការសិក្សា។ ការស្រាវជ្រាវតាមដានបន្ត បង្ហាញថាមាតាបិតាសិស្សបានចំណាយពេល នៅពេលយប់ដើម្បីជំរុញ ការសិក្សារបស់កូន ជាជាងការមើលទូរទស្សន៍។ មាតាបិតាខ្លះអាចជួយកូនខ្លួនក្នុងការធ្វើកិច្ចការសាលានៅផ្ទះ។ មាតាបិតាដែលធ្លាប់យល់ថាសាលារៀនបានឆក់យកពេលវេលាពីកូនពួកគេក្នុងការជួយធ្វើការនៅក្នុងវាលស្រែ នៅពេលនេះពួកគាត់ទទួលស្គាល់ភាពចាំបាច់ត្រូវមានតុល្យភាពរវាងចំណុចទាំងពីរ។ មាតាបិតាសិស្ស និង អ្នកដឹកនាំភូមិ បានយល់ដឹងថាពួកគេមានភារកិច្ចត្រូវធានាឲ្យបានថា កុមារត្រូវបានជំរុញឲ្យសិក្សា ដើម្បីអភិវឌ្ឍចំណេះដឹង និងជំនាញដែលពួកគេនឹងត្រូវការនៅក្នុងជីវិតពេញវ័យ។ ក្នុងន័យនេះ វិធីសាស្ត្រស្រាវជ្រាវតាមបែបចូលរួម រួមចំណែកដល់ផ្នែកទីបួននៃផែនការយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងគុណភាពនៃវិស័យអប់រំ ក៏ដូចជារួមចំណែកដល់ផែនការអភិវឌ្ឍន៍ជាតិ៕

> *"ខ្ញុំធ្លាប់បន្ទោសគ្រូបង្រៀននៅពេលដែលកូនរបស់ខ្ញុំរៀនមិនបានល្អ។ ប៉ុន្តែតាមរយៈកិច្ចប្រជុំជាមួយមាតាបិតា និងគ្រូបង្រៀន ដែលត្រូវបានរៀបចំដោយអង្គការ RDA កិច្ចប្រជុំនេះបានជួយខ្ញុំឲ្យបានយល់អំពីសារៈសំខាន់នៃតួនាទីរបស់ខ្ញុំក្នុងការជួយកូនខ្ញុំឲ្យរៀននៅផ្ទះ ជំនួសការបន្ទោសគ្រូបង្រៀន។វាគឺជាចំណែកមួយ នៃការទទួលខុសត្រូវរបស់ខ្ញុំ"*
> ប្រសាសន៍របស់អាណាព្យាបាលម្នាក់នៅភូមិប៉ោយរំដែ។

> *"ខ្ញុំយល់ថាក្នុងការប្រើ PAR គឺសំខាន់ណាស់ដែលយើងបានផ្លាស់ប្ដូរផ្នត់គំនិតរបស់សហគមន៍ ដែលពួកគេធ្លាប់គិតថា តួអង្គអភិវឌ្ឍន៍ត្រូវចុះមូលដ្ឋានដើម្បីផ្ដល់អំណោយឲ្យពួកគេ។ ពេលនេះ ពួកគេយល់ថាអង្គការមិនមែនរដ្ឋាភិបាល បានមកជួយឲ្យពួកគេយល់អំពីបញ្ហារបស់ពួកគេខ្លួនឯង និង របៀបដោះស្រាយ បញ្ហាដោយខ្លួនឯង"* ផាន់នី សិក្ខាមមកពីអង្គការ RDA។

# ការពង្រឹងកិច្ចគាំពារព្រៃឈើ និង សហគមន៍

ការស្រាវជ្រាវសម្របសម្រួលដោយៈ ឡុក កៀនស្រ៊ាន់ និង ភន រស្មី

ការរៀបចំសហគមន៍ព្រៃឈើ គឺក្នុងគោលបំណងចង់ឲ្យប្រជាពលរដ្ឋនៅតំបន់មានការចូលរួមជួយថែរក្សាការពារដើម្បីបន្សល់ទុកព្រៃឈើប្រើប្រាស់ឲ្យបានយូរអង្វែង សម្រាប់សហគមន៍ក៏ដូចជាប្រទេសជាតិទាំងមូលផងដែរ។ ទោះបីជាមានការផ្តើមក្នុងការរៀបចំសហគមន៍ព្រៃរួចហើយក៏ដោយនៅឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំងដែលមានចម្ងាយប្រមាណ ៩៨គីឡូម៉ែត្រពីទីរួមខេត្ត។ ជាងនេះ ភូមិច្រកកូវដែលជាភូមិមួយ ក្នុងចំណោមភូមិទាំង ១២នៅក្នុងឃុំ នៅតែមានបញ្ហាគួរឲ្យកត់សម្គាល់អំពីការបាត់បង់ព្រៃឈើ។ វាមានការកើនឡើងនូវ ការកាប់ព្រៃឈើយកទៅលក់កាន់តែកើនឡើង មានការរានព្រៃយកដីប្រជាពលរដ្ឋ ហើយប្រជាសហគមន៍និង គណៈ កម្មការក៏មិនពុំសូវមានការចូលរួមក្នុងការចុះល្បាត និងសហការគ្នាល្អការចាត់ចែងគណៈកម្មការពុំសូវមានភាពរឹងមាំក្នុងការដឹកនាំនិងពុំសូវមានទំនុកចិត្តលើខ្លួនឯង។ បញ្ហាទាំងនេះរិតតែធ្វើឲ្យមានការលំបាកយ៉ាងខ្លាំងដល់បញ្ហាធនធានសមាជិក ព្រៃឈើក្នុងសហគមន៍។



ប្រជាជននៅភូមិច្រកកូវ មានសរុបចំនួន ១ ៦០៤នាក់ ក្នុងឆ្នាំ២០១៣ ស្រ្តីចំនួន ៧៩០នាក់ ក្នុងនោះ មានស្រ្តីមេម៉ាយចំនួន ៦៤នាក់ ដែលមានខ្នងផ្ទះចំនួន ២៩២ សម្រាប់គ្រួសារចំនួន ៣១៦[3]។ ប្រជាពលរដ្ឋនៅក្នុង តំបន់នេះប្រកបមុខរបរធ្វើស្រែ ចំការជាចម្បង និងមុខរបរបន្ទាប់បន្សំមានដូចជា ចិញ្ចឹមសត្វ ដាំបន្លែ ធ្វើកម្មករកាប់អំពៅឱ្យក្រុមហ៊ុន ក្រៅពីនេះមានមុខរបរដែលទទួលផលបានមកពី សហគមន៍ព្រៃឈើ មានដូចជា៖ បេះផ្សិត វល្លិ៍ជីក ដំឡូង ទំពាំង ជាដើម។ ឆ្លងតាមការសិក្សាបឋម និងការឆ្លុះបញ្ចាំងផ្សេងៗក្រៅពីបញ្ហានេះ បញ្ហាផ្សេងៗទៀតក៏បានលើកឡើង ផងដែរដូចជា សត្វមានជំងឺ សុខភាពប្រជាពលរដ្ឋប្រព័ន្ធធារាសាស្រ្ត ផ្លូវថ្នល់និង ចំណាកស្រុកជាដើម។ តែអ្វីដែលគួរអោយកត់សម្គាល់ និង សម្រាប់ការចូលរួមសិក្សាស្រាវជ្រាវគឺ ការកាប់បំផ្លាញព្រៃឈើ និងការគ្រប់គ្រងរបស់សហគមន៍។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណង ដើម្បី ស្វែងយល់ពីមូលហេតុនៃការកាប់បំផ្លាញព្រៃឈើ ស្វែងរកផលប៉ះពាល់ទៅលើជីវភាពរស់នៅ របស់ប្រជាពលរដ្ឋដែលទាក់ទងទៅនឹងធនធានព្រៃឈើសហគមន៍ និងដើម្បីលើកកម្ពស់ការការពារ សហគមន៍ព្រៃឈើដោយប្រើប្រាស់វិធីសាស្រ្ត ការសិក្សាស្រាវជ្រាវ ដោយ

[3] ទិន្នន័យស្ថិតិឃុំពាម ឆ្នាំ២០១៣។

មានការចូលរួមដើម្បីធ្វើសកម្មភាព។ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានសម្របសម្រួលដោយបុគ្គលិកអង្គការ CCD ចំនួន២នាក់ និង អ្នកជំនួយបច្ចេកទេស ១ នាក់ពី អង្គការ CCC។ ការប្រមូលព័ត៌មានបានធ្វើឡើងអស់រយៈពេលបីថ្ងៃ ដែលមានការចូលរួមពីជនសំខាន់ៗ ដូចជា៖ បណ្តាញសហគមន៍ គណៈកម្មការសហគមន៍ព្រៃឈើថ្មី និងចាស់ មេភូមិ ក្រុមប្រឹក្សាឃុំ និងពាក់ព័ន្ធនានា ដើម្បីគូសផែនទី និងទីតាំងភូមិសាស្ត្រក្នុងតំបន់ និងបង្កើនទំនាក់ទំនងប្រជាពលរដ្ឋបានកាន់តែល្អ។ ក្រុមសិក្សាស្រាវជ្រាវបានស្នាក់នៅក្នុងភូមិ និងបានធ្វើការសម្ភាសន៍ជាមួយប្រជាពលរដ្ឋ ដែលមានការបែងចែកចំនួន៩ក្រុម ដើម្បីពិភាក្សាក្រុមដែលក្រុមខ្លះអាចមានចំនួនរហូតដល់១៥ទៅ២០នាក់ ព្រមទាំងធ្វើឲ្យការសម្ភាសន៍ស៊ីជំរៅក្នុងគោលបំណងទទួលបាននូវព័ត៌មានជាក់លាក់សមស្រប តាមសំនួរគន្លឹះដែលបានលើកឡើង។ បន្ទាប់ពីចូលរួមក្នុងដំណើរការនេះ ក្រុមអ្នកសិក្សាស្រាវជ្រាវបានចងក្រងរបាយការណ៍បញ្ចប់ទុកជាឯកសារ និងរៀបចំធ្វើ បទបង្ហាញលទ្ធផលទៅដល់សិក្ខាកាមក្នុងវគ្គ CPAR ផងដែរ។

## ការបំផ្លាញធនធានធម្មជាតិកើនឡើង ស្របពេលសកម្មភាពគណៈកម្មការសហគមន៍ធ្លាក់ចុះ



តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបានរកឃើញការងារសហការ និងការធ្លាក់ចុះនៃកិច្ចគ្រប់គ្រងរបស់សហគមន៍ព្រៃឈើ ជាឱកាសធ្វើឱ្យជនល្មើសកាប់បំផ្លាញព្រៃឈើ ហើយប៉ះពាល់ដល់ប្រជាពលរដ្ឋ ដែលជាសមាជិក សហគមន៍ទាំងមូល។ ការធ្លាក់ចុះនេះកើតឡើងតាំងពីមុនបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ ឆ្នាំ២០១២ មកម្លេះ ស្របពេលដែលការគាំទ្រពីខាងក្រៅ ត្រូវបានបញ្ចប់។ បច្ចុប្បន្ននេះការកាប់បំផ្លាញព្រៃសហគមន៍កាន់តែធ្ងន់ធ្ងរទៅៗ ដែលធ្វើឱ្យព្រៃឈើមានការបាត់បង់យ៉ាងច្រើន។ បទល្មើសភាគច្រើនបង្កឡើយដោយប្រជាពលរដ្ឋដែលជាសមាជិកក្នុងសហគមន៍នៅ ឃុំពាម ក៏ដូចជា ឃុំក្បែរគ្នានោះ ផងដែរមានដូចជា ឃុំស្វាយដុក និងឃុំក្រាំងល្វា។ ជារួមមានមូលហេតុសំខាន់ៗមួយចំនួនដែលបណ្តាលឱ្យមានការធ្លាក់ចុះនៃ សហគមន៍ និងព្រៃឈើមានដូចខាងក្រោម៖

- **ខ្វះការសហការណ៍ពីសមាជិកភូមិ៦ទៀត និង ប្រធានសហគមន៍ឃុំ:** កាលពីមុនមានការចុះល្បាតទៀងទាត់ហើយមានការសហការគ្នាបានល្អ រវាង សហគមន៍ទាំង៧ភូមិ រួមមាន ភូមិច្រកកូវ ច្រកស្តេច សិរីវង្ស ក្រាំងកន្ទោល ក្រាំងបេង ស្វាយកាំបិត និងភូមិ ច្រកកន្ទួត តែនៅពេលមុនការបោះឆ្នោតជ្រើសរើសឃុំ/សង្កាត់ ឆ្នាំ២០១២មក សហគមន៍ទាំង៧ភូមិ មិនបានចុះល្បាតទេ មានតែភូមិច្រកកូវមួយប៉ុណ្ណោះ ដែលចុះទៅការពារ។ ដោយមើលឃើញភាពអសកម្មនៃការល្បាតរបស់ភូមិទាំង៦ទៀត ប្រជាជនភូមិច្រកកូវក៏ឈប់ចុះទៅការពារដែរ ណា

មួយព្រៃសហគមន៍មានទំហំធំ មិនមានកំលាំង ចុះទៅការពារគ្រប់គ្រាន់។ ម្យ៉ាងទៀតដោយសារប្រធានសហគមន៍ចាស់ គាត់ទទួលមរណភាព ហើយអ្នកដែលឡើង មកកាន់តំណែងជំនួសថ្មីមិនសូវមានការគាំទ្របណ្តាល ឱ្យសហគមន៍អស់ទឹកចិត្ត។ ជាងនេះទៀត នៅរដូវធ្វើស្រែចំការប្រជាពលរដ្ឋរវល់នឹងការប្រកបកិច្ចការផ្ទាល់ខ្លួន នាំអោយខ្វះកំលាំង ចូលរួមចុះល្បាតព្រៃសហគមន៍ និងធ្វើអោយបទល្មើសកាន់តែកើនឡើង។

- **ការគម្រាមកំហែងពីជនល្មើស និងមានការគាំទ្រតិចតួចពីអាជ្ញាធរមូលដ្ឋានៈ** កន្លងមកការចុះល្បាតរបស់សហគមន៍តែងតែជួបនូវឧបសគ្គជាច្រើន ដូចជា ការគម្រាមកំហែងពីជនល្មើសចំណែកឯកំលាំងចុះល្បាតសហគមន៍មានគ្នាតិច នៅពេលខ្លះពាក្យសម្តីមានពាក្យសម្តី ការដេញកាប់ពីខាងជនល្មើស និងគម្រាមកំហែងដល់អាយុជីវិតរបស់សហគមន៍។ ម្យ៉ាងទៀតនៅពេលជួបជនល្មើស អាជ្ញាធរដូចជា ក្រុមប្រឹក្សាឃុំ ប៉ូលីស មន្ត្រីឃុំ មិនមានការសហការល្អក្នុងការធ្វើអន្តរាគមន៍ ធ្វើឱ្យសហគមន៍ខ្លាច និងបាក់ទឹកចិត្តក្នុងការការពារព្រៃរបស់សហគមន៍។
- **គណៈកម្មការសហគមន៍គ្មានសិទ្ធិ និងអំណាចលើការចាប់ជនល្មើសៈ** ពេលកំលាំងការពារសហគមន៍ចុះល្បាតព្រៃភាគច្រើននៃជនល្មើស ដែលសហគមន៍ចាប់ និងឃាត់ខ្លួនបានបញ្ជូនទៅឱ្យខាងអាជ្ញាធរជាអ្នកដោះស្រាយ តែការដោះស្រាយលើបទល្មើសព្រៃឈើ អាជ្ញាធរមិនបានហៅតំណាងសហគមន៍ឱ្យចូលរួមដោះស្រាយទេ តែបានដោះស្រាយជាមួយ នឹងជនល្មើសត្រឹមតែទទួលលុយបង់ការផាកពិន័យបន្តិចបន្តួចរួចក៏ដោះលែងជនល្មើសឲ្យរួចខ្លួន នេះជាហេតុធ្វើឱ្យសហគមន៍ការពារពួកគាត់អស់ទឹកចិត្តក្នុងការការពារព្រៃសហគមន៍តទៅទៀត។
- **សហគមន៍ទាំង៦ភូមិមិនទាន់ស្គាល់ប្រធានសហគមន៍ឃុំថ្មីៈ** ក្រោយពីប្រធានសហគមន៍ឃុំចាស់បានទទួលមរណភាពទៅ ក្រុមប្រឹក្សាឃុំបានប្រជុំពិភាក្សាគ្នាជ្រើសតាំងប្រធានថ្មីតែការជំនួសតំណែងនេះ ប្រធានសហគមន៍ភូមិទាំង៦មិនបានទទួលពត៌មានទេ ហើយសហគមន៍ទាំង៦ភូមិក៏មិនមានការចុះល្បាតដែរ។ ឯខាងរដ្ឋបាលព្រៃឈើក៏មិនទាន់បានដឹង នឹងមិនទាន់ទទួលស្គាល់ប្រធានសហគមន៍ឃុំថ្មីដែរ មានតែសហគមន៍ភូមិច្រកក្កូរតែមួយប៉ុណ្ណោះដែលទទួលបានព័ត៌មាននេះ។
- **សហគមន៍មានការខ្វះថវិកាៈ** ដោយសារតែព្រៃសហគមន៍នៅឆ្ងាយពីភូមិ នៅពេលចុះទៅល្បាតត្រូវចំណាយថវិកាសម្រាប់ការចាក់សាំងម៉ូតូ ជិះទៅតំបន់ការពារ។ កាលពីឆ្នាំកន្លងទៅមានការគាំទ្រថវិកាពីអង្គការផ្សេងៗដូចជា JICA អង្គការ LWD អង្គការ GF និងអង្គការ CCD បានធ្វើឱ្យសហគមន៍មានភាពរឹងមាំ សហការគ្នាបានល្អ និងចុះល្បាតបានទៀង ទាត់។ ប៉ុន្តែក្រោយពីអង្គការទាំងនោះបាន ដកចេញទៅ សកម្មភាពរបស់សហគមន៍បានចុះខ្សោយហើយការការពារព្រៃមិនក៏មិនបានទៀតទាត់ដែរ។

# សហគមន៍រួមគ្នាដើម្បីការពារធនធានព្រៃឈើ កាន់តែប្រសើរ

ក្រោយពីការប្រជុំភូមិ ដើម្បីពិភាក្សា និងវិភាគលទ្ធផល សម្រាប់ឈានដល់ផែនការដោះស្រាយបញ្ហា ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធរួចមកក៏មានគម្រោងផែនការសកម្មភាព និងអនុវត្តក្នុងការ ការពារព្រៃសហគមន៍ភូមិច្រកកូវ ឃុំពាមត្រូវបានកំណត់ដូចជា៖

*"ការការពារព្រៃឈើ នៅក្នុងសហគមន៍ភ្នំព្រះធាតុនេះ បានផ្តល់ប្រយោជន៍ច្រើនដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នេះ និងឃុំដូចជា ប្រជាពលរដ្ឋដែល មិនមានមុខរបរ ឬអ្នកទីទាល់ក្រ អាចប្រើប្រាស់ធនធានទាំងនេះ [ជីកទំពាំង ដំឡូងបោចវល្លិ៍ កាប់ឫស្សី] សម្រាប់លក់ ប្រចាំថ្ងៃផ្តល់ឈើសម្រាប់ធ្វើផ្ទះ អុសដុតបង្គោលរបង ជាជម្រកសត្វព្រៃ ទាក់ទាញទឹកភ្លៀង ការពារសំណឹកដី ការពារខ្យល់ព្យុះ ជាកន្លែងសម្រាប់ឃ្វាលគោក្របី ការពារថ្មភ្នំ ម្យ៉ាងទៀតទាក់ទាញភ្ញៀវទេសចរណ៍មកទស្សនា "* សារ៉េម ភូមិច្រកកូវ។



- ប្រជុំគណៈកម្មការសហគមន៍ព្រៃឈើទាំង ៧ភូមិធ្វើការណែនាំ ពីប្រធានសហគមន៍ព្រៃឈើឃុំថ្មី និងដើម្បីពិភាក្សាពង្រឹងសកម្មភាព ការពារព្រៃឈើឡើងវិញ។ ហើយសកម្មភាពនេះ បានអនុវត្តក្នុងខែមិថុនា ឆ្នាំ២០១៣ ដោយក្រោមការសម្របសម្រួលរបស់ ប្រធានក្រុមប្រឹក្សាឃុំ ព្រមទាំងមានការចូលរួមពីសហគមន៍ទាំង ៧ និងតំណាង៧រូបផ្សេងទៀត។ ជាលទ្ធផលគណៈកម្មការ សហគម៍ព្រៃឈើទាំង៧ភូមិទទួលស្គាល់ប្រធានសហគមន៍ថ្មី ព្រមទាំងធ្វើការរៀបចំ សមាសភាព គណកម្មការថ្មី និងរៀបចំការកែសម្រួល លើការបែងចែកភារកិច្ច និងការទទួលខុសត្រូវដើម្បីដំណើរការសកម្មភាពបាន ប្រសើរជាងមុន។
- កៀរគរមូលនិធិបដិភាគពីប្រជាពលរដ្ឋ ដើម្បីគាំទ្រដល់ព្រៃសហគមន៍ នៅភូមិច្រកកូវ ក្រោមការជួយសម្របសម្រួលរបស់អាជ្ញាធរភូមិ។ ដូច្នេះហើយប្រជាពលរដ្ឋមួយចំនួនបាន បរិច្ចាគថវិកាផ្ទាល់ខ្លួន ដើម្បីទុកក្នុងកញ្ចប់ថវិកាសហគមន៍សម្រាប់បម្រើការងារចុះល្បាត និងទប់ស្កាត់បទល្មើស។
- សម្រាប់សមាសភាពថ្មីក្នុងជួរគណៈកម្មការសហគមន៍ ដូច្នេះហើយក៏មានការស្នើអោយមានការបើកវគ្គបណ្តុះបណ្តាលអំពីច្បាប់ និងការគ្រប់គ្រងព្រៃឈើ ក្រោមការជួយសម្របសម្រួលរបស់ប្រធានក្រុមប្រឹក្សាឃុំ និងសហគមន៍ជាអ្នកទទួលខុសត្រូវ។ ទោះមានការទំនាក់ទំនងជាបន្តបន្ទាប់ពីការសម្របសម្រួល តែមិនទាន់មានពេលសមស្របសម្រាប់ការផ្តល់ការបណ្តុះបណ្តាលពីអ្នកជំនាញពីរដ្ឋបាលព្រៃឈើ រហូតមកដល់ខែសីហា ដំណើការនេះមិនទាន់បានសម្រេចនៅឡើយ។ តែអង្គការដែលជួយសម្របសម្រួលក្នុងតំបន់នឹងបន្តជំរុញការងារនេះបន្ថែមទៀត។

ជារួមតាមរយៈលទ្ធផលខាងលើនេះ យើងសង្កេតឃើញថាការប្រើប្រាស់វិធីសាស្ត្រ PAR បាននាំពួកគេចូលរួមជាមួយអ្នកពាក់ព័ន្ធផ្សេងៗដូចជាអាជ្ញាធរមូលដ្ឋាន និងជំរុញឱ្យសហគមន៍ ក៏ដូចជាប្រជាពលរដ្ឋមានភាពជាម្ចាស់ការខ្លួនឯង ក្នុងការដោះស្រាយបញ្ហាដែលកើតមាននៅក្នុងសហគមន៍ និងធ្វើឱ្យសហគមន៍មានភាពរឹងមាំឡើងវិញប្រកបដោយ ប្រសិទ្ធិភាព និងមាននិរន្តរភាពនៅថ្ងៃអនាគត។ ជាងនេះទៀតនេះយើងអាចទាញបាននូវ មេរៀនជាបទពិសោធន៍មួយចំនួនដូចជា: ដើម្បីឱ្យការសិក្សាស្រាវជ្រាវនៅក្នុងសហគមន៍មួយទទួលបានជោគជ័យ អ្នកសិក្សាគ្រប់រូប ត្រូវគិតទៅលើប្រធានបទដែលត្រូវសិក្សាដោយគិតទៅលើទំហំបញ្ហា ដែលកើតមាននៅក្នុងសហគមន៍ ហើយសហគមន៍នោះចង់ដោះស្រាយដោយខ្លួនឯង ទើបធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវ មានភាពងាយស្រួល ហើយអ្នកសិក្សាស្រាវជ្រាវត្រូវជៀសវាង ការអនុវត្តន៍សកម្មភាពនៃការសិក្សាស្រាវជ្រាវនៅរដូវវស្សា និង កៀកពេលនឹងការបោះឆ្នោតជាតិ ឬឃុំ/សង្កាត់៕

## ឧបសម្ព័ន្ធ ១: អង្គការជាសិក្ខាកាម

| លរ | ឈ្មោះ | ភេទ | តួនាទី | ឈ្មោះ អង្គការ | ទីតាំង |
|---|---|---|---|---|---|
| 1 | ម៉ែន សំភ័ណ | ស | បុគ្គលិកសហគមន៍ | ជួយជនចាស់ជរាអន្តរជាតិ-កម្ពុជា | បាត់ដំបង |
| 2 | ខ្លូត ផល្លី | ស | បុគ្គលិកសហគមន៍ | | |
| 3 | មៅ គង្គា | ស | បុគ្គលិកស្ម័គ្រចិត្ត | | |
| 4 | ស៊ុម ផាន់នី | ប | ប្រធានកម្មវិធី | សមាគមអភិវឌ្ឍន៍ស្រុកស្រែ | បាត់ដំបង |
| 5 | ស្រូយ វ៉ាន់ស៊ី | ស | ប្រធានកម្មវិធី | | |
| 6 | យឹន សម័យ | ប | អ្នកសម្របសម្រួលកម្មវិធី | អ្នកអភិវឌ្ឍសហគមន៍ | កំពង់ចាម |
| 7 | សេង សុភារិទ្ធិ | ប | អ្នកសម្របសម្រួលកម្មវិធី | | |
| 8 | ហឹងសុដារិន | ស | អ្នកសម្របសម្រួលកម្មវិធី | សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍសង្គម | កំពង់ចាម |
| 9 | ផាន សុធា | ប | បុគ្គលិកសម្របសម្រួលកម្មវិធី | | |
| 10 | ភន រស្មី | ប | បុគ្គលិកកម្មវិធី | បង្កើនសមត្ថភាពសហគមន៍ដើម្បីអភិវឌ្ឍន៍ | កំពង់ឆ្នាំង |
| 11 | ឡុក កៀនស្រ៊ាន់ | ប | បុគ្គលិកកម្មវិធី | | |
| 12 | ង៉ែត រិទ្ធី | ប | ជំនួយការកម្មវិធី | សេវាកម្មអភិវឌ្ឍជនពិការ | ពោធិ៍សាត់ |
| 13 | ឡី ហៀប | ស | ជំនួយការកម្មវិធី | | |
| 14 | កែ សុភា | ស | បុគ្គលិក | អនាគតកុមារ | ពោធិ៍សាត់ |
| 15 | ជា ស្រីនាង | ស | បុគ្គលិក | | |

## ឧបសម្ព័ន្ធ ២: ក្រុមការងាររបស់អង្គការ CCC

| លរ | ឈ្មោះ | ភេទ | តួនាទី | ឈ្មោះ អង្គការ | ទីតាំង |
|---|---|---|---|---|---|
| 1 | ជេន សុជឿន | ប | អ្នកជំនាញសិក្សាស្រាវជ្រាវ | CCC | ភ្នំពេញ |
| 2 | ឆោម ចរិយា | ស | មន្ត្រីសិក្សាស្រាវជ្រាវ | CCC | ភ្នំពេញ |
| 3 | ហោ សុគន្ធា | ស | អ្នកជំនាញអភិវឌ្ឍនិងផ្សព្វផ្សាយ | CCC | ភ្នំពេញ |
| 4 | ជា វិបុល | ប | មន្ត្រីអភិវឌ្ឍនិងផ្សព្វផ្សាយ | CCC | ភ្នំពេញ |
| 5 | លឹម សុខលី | ប | អ្នកជំនាញសិក្សារៀនសូត្រ | CCC | ភ្នំពេញ |
| 6 | អែល សុធារី | ស | ប្រធានកម្មវិធី | CCC | ភ្នំពេញ |
| 7 | សឿង ទីប៉ូ | ប | ប្រធានផ្នែកអភិវឌ្ឍនិងរៀនសូត្រ | CCC | ភ្នំពេញ |

**ទស្សនវិស័យ**:

សង្គមស៊ីវិលមួយដែលមាន កិច្ចសហការដ៏រឹងមាំ និង មានសមត្ថភាពឆ្លើយតបទៅនឹង បញ្ហានៃការអភិវឌ្ឍនៅកម្ពុជា។

**បេសកកម្ម**:

ក្នុងឋានៈជាសមាគមដែលមានវិជ្ជាជីវៈមួយនៃ អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ផ្តល់សេវាកម្មប្រកបដោយគុណភាពខ្ពស់ជូនដល់សង្គមស៊ីវិល និង បង្កលក្ខណៈឱ្យមានឥទ្ធិពលដល់ដៃគូ អភិវឌ្ឍនៃប្រទេសកម្ពុជា ជាមួយនឹងសំលេងរួមគ្នារបស់យើង។

**គុណតម្លៃ**:

☆ សុច្ចរិតភាព
☆ កិច្ចសហប្រតិបត្តិការ
☆ ភាពឆ្លើយតប
☆ គុណភាព

ផ្ទះលេខ ៩-១១, ផ្លូវលេខ ៤៧៦, ទួលទំពូងទី១, ខណ្ឌចំការមន
ប្រអប់សំបុត្រ ៨៨៥, ភ្នំពេញ កម្ពុជា
ទូរស័ព្ទ +855 (0)23 214 152
ទូរសារ +855 (0)23 216 009
info@ccc-cambodia.org
www.ccc-cambodia.org
www.facebook.com/CCCsince1990
www.youtube.com/CCCambodia